


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

Cambodian League for the Promotion and Defense of Human Rights


# ការរួចខ្លួនពីបទល្មើស៖

## ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈ ក្នុងប្រព័ន្ធតុលាការកម្ពុជា


របាយការណ៍ចេញផ្សាយ
ខែវិច្ឆិកា ឆ្នាំ២០១៥

# ការរួចខ្លួនពីបទល្មើស៖

## ការអនុវត្តច្បាប់ចំពោះបទល្មើសរំលោភសេពសន្ថវៈ

## ក្នុងប្រព័ន្ធតុលាការកម្ពុជា

របាយការណ៍ចេញផ្សាយ ខែវិច្ឆិកា ឆ្នាំ២០១៥


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ មក អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ:**
បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយអាជ្ញាធរ ការរំលោភបំពានលើស្ត្រី និងកុមារ។ ជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ច:**
ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហារសម្រាប់រយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារ:**
អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:**
ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ និងផ្តល់ជូនមេធាវីសិទ្ធិមនុស្សសម្រាប់ជាតំណាងផ្លូវច្បាប់លើករណីសំខាន់ៗមួយចំនួន។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្តាញនានា:**
ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារ សេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:**
បុគ្គលិកតស៊ូមតិធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្តាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីជួយកែលំអសង្គមនិងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**គាំទ្រការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:**
ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេតដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

វិធីសាស្រ្តសិក្សា ទំព័រ២

ទិដ្ឋភាពទូទៅនៃករណីទាំងអស់ ទំព័រ៣

ប្រភេទនៃករណីដែលត្រូវបិទ ៦

លទ្ធផលនៃករណីទាំងអស់ដែលត្រូវបានបិទ ៧

ភាពខុសគ្នារវាងករណីដែលជាប់ពាក់ព័ន្ធនឹង ស្រ្តី និងកុមារ ៧

អំពើពុករលួយ ទំព័រ១០

ការបញ្ចប់រឿងក្តីដោយសំណង ទំព័រ១១

ការបង់ប្រាក់ក្រៅច្បាប់ទៅឲ្យមន្ត្រីនានា ១១

ហេតុអ្វីបានជាជនរងគ្រោះយល់ព្រមបញ្ចប់ រឿងក្តីដោយប្រាក់សំណង ១២

ការបង់ប្រាក់សំណង និងច្បាប់ ១៤

ផលប៉ះពាល់អវិជ្ជមាននៃការបង់ ប្រាក់សំណង ១៦

ការរៀបអាពាហ៍ពិពាហ៍ជនរងគ្រោះ ជាមួយជនសង្ស័យ ទំព័រ១៦

ការរំលោភសេពសន្ថវៈក្នុងចំណង អាពាហ៍ពិពាហ៍ ទំព័រ១៨

មិនមានពាក្យបណ្តឹងត្រូវបានដាក់ ឬត្រូវបានដក ទំព័រ១៩

បទប្រទូស្តកេរខ្មាស ទំព័រ២១

អាយុជនរងគ្រោះ ទំព័រ២៣

ការព្យួរទោស ទំព័រ២៤

ទោសពន្ធនាគាររយៈពេលខ្លី ទំព័រ២៥

អំពីរំលោភសេពសន្ថវៈ ដែលមានគ្នាច្រើន ទំព័រ២៦

សាលក្រមគ្មានទោស ទំព័រ២៧

សេចក្តីបញ្ចប់ ទំព័រ២៩

អនុសាសន៍ ទំព័រ៣០




កុមារីរងគ្រោះដោយករណីរំលោភសេពសន្ថវៈ



អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ និងជនរងគ្រោះ នៅប៉ុស្តិ៍នគរបាល

# សេចក្តីផ្តើម

នៅក្នុងឆ្នាំ២០១៣ អង្គការសហប្រជាជាតិ បានបោះពុម្ពផ្សាយការស្រាវជ្រាវស្តីពី ការរីកសាយនៃការប្រើប្រាស់អំពើហិង្សារបស់បុរសកម្ពុជាទៅលើស្ត្រី។ ការស្រាវជ្រាវនេះបានរកឃើញថា ក្នុងចំណោមបុរសដែលត្រូវបានសម្ភាសន៍ចំនួន ១៨១២ នាក់ មានបុរសចំនួន ៣៦៩ នាក់ (២០.៤%) បានទទួលស្គាល់ថា អ្នកទាំងនោះបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ តួលេខនេះ រួមបញ្ចូលទាំងការរំលោភទៅលើដៃគូ ការរំលោភទៅលើអ្នកដែលមិនមែនជាដៃគូ និងការរំលោភជាក្រុម ឬ រំលោភបូក។ ក្នុងចំណោមបុរសចំនួន៣៦៩នាក់នេះ មានបុរសចំនួនជិតពាក់កណ្តាល ធ្លាប់បានរំលោភសេពសន្ថវៈច្រើនជាងមួយដង និងបុរសចំនួនច្រើនជាង ២០% ធ្លាប់បានរំលោភសេពសន្ថវៈលើជនរងគ្រោះច្រើនជាងមួយនាក់។[9] តួលេខទាំងនេះបង្ហាញថាការចាប់រំលោភសេពសន្ថវៈ គឺជាបញ្ហាធ្ងន់ធ្ងរនិងរីករាលដាលនៅក្នុងប្រទេសកម្ពុជា និងក្រៅពីនេះក៏នៅតែមានកង្វះខាតក្នុងការផ្តល់សេវាកម្មគ្រប់ប្រភេទ សម្រាប់ជនរងគ្រោះដោយការរំលោភសេពសន្ថវៈ ហើយការអនុវត្តច្បាប់ គឺនៅតែមិនទាន់បានគ្រប់គ្រាន់នៅឡើយទេ។

នៅក្នុងប្រទេសកម្ពុជា មិនមានប្រព័ន្ធកណ្តាលមួយដែលអាចទុកចិត្តបាន សម្រាប់កត់ត្រាទិន្នន័យអំពីករណីរំលោភសេព-សន្ថវៈ ឬ ធ្វើការតាមដានលទ្ធផលនៃករណីទាំងនោះនោះទេ។ កង្វះនៃទិន្នន័យទាំងនេះ ធ្វើឲ្យមានភាពងាយស្រួលក្នុងការមិនយកចិត្តទុកដាក់អំពីកម្រិតនៃបញ្ហា និង ទំហំនៃគុណវិបត្តិនានា នៅពេលបច្ចុប្បន្ន នៅក្នុងការអនុវត្តច្បាប់របស់អាជ្ញាធរលើករណីរំលោភសេព-សន្ថវៈ។ ខណៈពេលដែលមិនមានអ្វីសម្រាប់ជំនួសប្រព័ន្ធកណ្តាលបែបនេះ ការងាររបស់អង្គការលីកាដូ ក្នុងការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈ និងជួយគាំទ្រដល់ជនរងគ្រោះ បង្ហាញថាអង្គការលីកាដូគឺជាស្ថាប័នល្អមួយ ដើម្បីធ្វើការពិនិត្យនិងអត្ថាធិប្បាយលើការអនុវត្តនាពេលបច្ចុប្បន្នចំពោះករណីរំលោភសេពសន្ថវៈក្នុងប្រទេសកម្ពុជា។

របាយការណ៍នេះ ត្រូវបានផ្អែកលើការវិភាគទិន្នន័យអំពីករណីរំលោភសេពសន្ថវៈជាច្រើន ដែលត្រូវបានប្រមូល ដោយអង្គការលីកាដូ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយនេះ។ របាយការណ៍ការនេះបង្ហាញអំពីកំហុសឆ្គងធ្ងន់ធ្ងរ និងជាប្រព័ន្ធជាច្រើន នៅក្នុងការកាត់ទោសលើករណីរំលោភសេពសន្ថវៈ ដែលបណ្តាលឲ្យការផ្តន្ទាទោសលើករណីទាំងនេះនៅមានចំនួនទាបគួរឲ្យព្រួយបារម្ភ។ មូលហេតុជាច្រើនពាក់ព័ន្ធនឹងកំហុសឆ្គងទាំងនេះ គឺខុសៗប្លែកពីគ្នា ប៉ុន្តែក្នុងចំណោមកត្តាសំខាន់ៗបំផុត គឺមានដូចជាករណីមួយចំនួនធំត្រូវបានដោះស្រាយដោយសំណងជាប្រាក់ ការរីករាលដាលផលប៉ះពាល់អវិជ្ជមាននៃអំពើពុករលួយ ក្នុងចំណោមនគរបាល និងតុលាការកង្វះខាតការយល់ដឹង និងការអនុវត្តច្បាប់ដោយចៅក្រម និងផលប៉ះពាល់អវិជ្ជមាននៃឥរិយាបទរើសអើងចំពោះស្ត្រី និងជាពិសេសចំពោះផ្លូវភេទរបស់ស្ត្រី។

[9] Partners for Prevention, Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the UN Multi-country Study on Men and Violence in Asia and the Pacific, September 3013, p.40-43, http://www.partners4prevention.org/node/515.

ខណៈពេលជាង ១១ ឆ្នាំបានកន្លងផុតចាប់តាំងពីមានរបាយការណ៍ចុងក្រោយ ស្តីពីការរំលោភសេពសន្ថវៈរបស់អង្គការលីកាដូ[២] មានការព្រួយបារម្ភជាខ្លាំង នៅពេលដែលកត់សម្គាល់ឃើញថា បញ្ហាដែលត្រូវបានរកឃើញមិនមានការផ្លាស់ប្តូរ ហើយហាក់បីដូចជាមានការរីកចំរើនតិចតួចណាស់ទៅលើស្ថានភាពនេះ។ អង្គការលីកាដូ ទទួលស្គាល់ថាចរិកលក្ខណៈ និងទំហំនៃបញ្ហាបានបង្ហាញឲ្យឃើញពីបញ្ហាប្រឈមជាច្រើន ហើយការផ្លាស់ប្តូរនឹងមិនមានភាពងាយស្រួលនោះទេ។ ប៉ុន្តែការខ្វះខាតនៃកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវការផ្លាស់ប្តូរ និងការខ្វះខាតជាក់ស្តែងនៃឆន្ទៈ គឺរឹតតែគួរឲ្យព្រួយបារម្ភយ៉ាងខ្លាំងថែមទៀត។ របាយការណ៍នេះនឹងបញ្ចប់ដោយមានអនុសាសន៍ជាក់ស្តែងជាបន្តបន្ទាប់ ផ្ញើជូនទៅកាន់រាជរដ្ឋាភិបាលកម្ពុជា។ ប្រសិនបើអនុសាសន៍ទាំងនេះត្រូវបានអនុវត្តតាម នោះនឹងធ្វើឲ្យមានការចាប់ផ្តើមការផ្លាស់ប្តូរមួយ។


កាសែតភាសាខ្មែរទាំងអស់ ចាប់ពីខែកញ្ញា ឆ្នាំ២០១៥ ចេញផ្សព្វផ្សាយពីករណីរំលោភសេពសន្ថវៈ

# វិធីសាស្ត្រសិក្សា

អង្គការលីកាដូ បានធ្វើការសើបអង្កេតពីករណីចាប់រំលោភសេពសន្ថវៈលើស្ត្រី និងកុមារអស់រយៈពេលជាង ២០ ឆ្នាំមកហើយ។ បច្ចុប្បន្ននេះ អង្គការលីកាដូ មានការិយាល័យក្នុងរាជធានីភ្នំពេញ និងការិយាល័យនៅតាមបណ្តាខេត្តចំនួន ១៣ ខេត្ត។ គ្រប់ការិយាល័យទាំងអស់ ធ្វើការស៊ើបអង្កេតករណីរំលោភសេពសន្ថវៈលើកុមារក្រោមអាយុ ១៨ ឆ្នាំ និងលើស្ត្រីអាយុ ១៨ ឆ្នាំ និងលើសពី ១៨ឆ្នាំ។ អង្គការលីកាដូ ទទួលបានករណីទាំងនេះ ពីប្រភពខុសៗគ្នា ដែលក្នុងនោះរួមមាន ការស្នើសុំដោយផ្ទាល់ពីជនរងគ្រោះ ឬ ពីសាច់ញាតិរបស់ជនរងគ្រោះ ការជូនដំណឹងពីអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ និងសេចក្តីរាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។ ជាផ្នែកមួយនៃការស៊ើបអង្កេត អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សរបស់អង្គការ លីកាដូ ធ្វើការសម្ភាសន៍ជាមួយនឹងជនរងគ្រោះ និងសាក្សីហើយធ្វើការកត់ត្រាអង្គហេតុនៃករណីនីមួយៗ ធ្វើការទាក់ទងទៅនគរបាល និងព្រះរាជអាជ្ញា ដើម្បីធានាថាការស៊ើបអង្កេតត្រូវបានអនុវត្ត ផ្តល់សេវាកម្មផ្លូវច្បាប់ជូនទៅដល់អតិថិជន ឬ ណែនាំអ្នកទាំងនោះទៅអង្គការដទៃទៀតដែលផ្តល់សេវាកម្មប្រភេទនេះ ផ្តល់ការព្យាបាលបែបសង្គ្រោះ បន្ទាន់និងផ្តល់ជំនួយសម្ភារៈមូលដ្ឋាន បញ្ជូនកូនក្តីទៅកាន់ទីជម្រកប្រសិនបើចាំបាច់និងតាមដានករណីជាមួយអាជ្ញាធរ ដើម្បីធានាថាជំហានទាំងអស់ត្រូវបានអនុវត្ត ក្នុងការស៊ើបអង្កេត និងកាត់ទោសជនល្មើស។

នៅពេលដែលករណីមួយត្រូវបានបើក ព័ត៌មានអំពីករណីនេះត្រូវបានកត់ត្រាទុកនៅក្នុងប្រព័ន្ធទិន្នន័យកណ្តាលមួយ។ ជា

[២] អង្គការលីកាដូ, បទរំលោភសេពសន្ថវៈ និងបទប្រទូស្តកេរខ្មាស, ខែមិនា ឆ្នាំ២០០៤, https://www.licadho-cambodia.org/reports/files/48Rape%20briefing%20report%202003%20English.pdf.

ទៀងទាត់ អ្នកឃ្លាំមើលផ្ញើរបាយការណ៍ដែលកំពុងតាមដានជាច្រើន ហើយដែលនឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ។ នៅពេលដែលករណីនេះត្រូវបានបញ្ចប់ ព័ត៌មានត្រូវបានកត់ត្រាអំពីរបៀបដែលករណីនេះត្រូវបានបិទ។ ព័ត៌មានអំពីករណីរំលោភសេពសន្ថវៈ និងករណីប៉ុនប៉ងរំលោភសេពសន្ថវៈទាំងអស់ ដែលត្រូវបានបើកដោយអង្គការ លីកាដូ នៅឆ្នាំ ២០១២ ២០១៣ និងឆ្នាំ ២០១៤ បង្កើតជាមូលដ្ឋានគ្រឹះនៃរបាយការណ៍នេះ។ ពីព្រោះរបាយការណ៍នេះ គឺផ្អែកតែទៅលើករណីជាច្រើន ដែលត្រូវបានស៊ើបអង្កេតដោយផ្ទាល់ដោយអង្គការ លីកាដូ ដូចនេះមិនអាចចាត់ទុកថាជាការពិនិត្យមើលឲ្យបានគ្រប់ជ្រុងជ្រោយចំពោះករណីរំលោភសេពសន្ថវៈដែលត្រូវបានរាយការណ៍ទាំងអស់នៅក្នុងប្រទេសកម្ពុជានោះទេ។

ដើម្បីធានាថាព័ត៌មាននេះនៅថ្មី (ធ្វើបច្ចុប្បន្នភាព) និងគ្រប់ជ្រុងជ្រោយ នៅក្នុងចន្លោះពេលពីខែមិថុនា ដល់ខែសីហា ឆ្នាំ ២០១៥ អ្នកឃ្លាំមើល របស់អង្គការលីកាដូ ត្រូវបានស្នើឲ្យផ្តល់ព័ត៌មានលម្អិតអំពីបញ្ជីករណីរបស់អ្នកទាំងនោះក្នុងចន្លោះពេលនោះ។ ជាផ្នែកមួយនៃដំណើរការនេះ អ្នកឃ្លាំមើលទាំងនោះត្រូវបានសម្ភាសន៍អំពីករណីនីមួយៗ និងត្រូវបានស្នើឲ្យ ចែករំលែកបទពិសោធន៍របស់ពួកគេក្នុងការងារធ្វើការលើករណីរំលោភសេពសន្ថវៈ។ បទពិសោធន៍ទាំងនេះក៏បានរួមចំណែកបង្កើតជាមាតិកានានា នៅក្នុងរបាយការណ៍នេះផងដែរ។



សាលាដំបូងរាជធានីភ្នំពេញ

# និន្នាការទូទៅនៃករណីទាំងអស់

ចន្លោះពីដើមឆ្នាំ ២០១២ ដល់ចុងឆ្នាំ ២០១៤ អង្គការលីកាដូ បានស៊ើបអង្កេតលើករណីនៃបទរំលោភសេពសន្ថវៈ ឬ បទប៉ុនប៉ងរំលោភសេពសន្ថវៈចំនួន ២២៥ករណី ដែលពាក់ព័ន្ធ និងស្ត្រីអាយុ ១៨ ឆ្នាំ ឬលើសពី ១៨ ឆ្នាំ ហើយនិង ៥៣៧ ករណី ដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ ឆ្នាំ។ ក្នុងចំណោម ២២៥ ករណីនៃបទរំលោភសេពសន្ថវៈលើមនុស្សពេញវ័យ ១៣១ ករណី ត្រូវបានបិទ និងក្នុងចំណោម ៥៣៧ ករណីនៃបទរំលោភសេពសន្ថវៈលើកុមារ ២៩៣ ករណី ត្រូវបានបិទ។[៣] របាយការណ៍នេះនឹងផ្តោតសំខាន់លើលទ្ធផលនៃករណីដែលបានបិទ ប៉ុន្តែវាក៏មានតំលៃផងដែរក្នុងការពិនិត្យទៅលើនិន្នាការចម្បងៗនៅក្នុងករណីទាំងអស់ ដែលត្រូវបានបើកនៅក្នុងចន្លោះពេលនោះ ដោយសារតែវាក៏បង្ហាញពីផលលំបាកមួយចំនួនកើតមានឡើងនៅជុំវិញការរាយការណ៍ និងការកាត់ទោសនៃបទល្មើសរំលោភសេពសន្ថវៈ។

ដំបូងបង្អស់ ចំនួននៃករណីដែលនៅតែកំពុងបើកគឺមានចំនួនច្រើនណាស់ ដែលនេះជាការផ្តល់នូវសញ្ញាបង្ហាញអំពីភាពយឺតយ៉ាវរបស់ប្រព័ន្ធតុលាការ ក្នុងផ្នែកព្រហ្មទណ្ឌចំពោះនីតិវិធីលើបទល្មើសរំលោភសេពសន្ថវៈ។ អ្នកឃ្លាំមើលរបស់អង្គការលីកាដូជា

[៣] មិនមែនគ្រប់ករណីទាំងអស់នៃករណីដែលត្រូវបានបិទ មានបញ្ចូលការវិភាគលើលទ្ធផលនោះទេ។ ករណីចំនួន ៨ មិនមានការវិភាគលទ្ធផលនោះទេ នៅពេលដែលករណីទាំងនោះត្រូវបានបិទនៅក្នុងប្រព័ន្ធទិន្នន័យ ដោយសារបុគ្គលិកអង្គការ លីកាដូ មិនអាចទទួលបានព័ត៌មានគ្រប់គ្រាន់ ឬច្បាស់លាស់ថាតើករណីទាំងនោះត្រូវបានបិទដោយសារមូលហេតុអ្វី។

## ជនសង្ស័យដែលបានរត់គេចខ្លួន

ក្មេងស្រីអាយុ ១៥ ឆ្នាំ ម្នាក់ គឺជាជនរងគ្រោះនៃការប៉ុនប៉ងរំលោភសេពសន្ថវៈ ដោយឪពុករបស់នាងដែលជាទាហាន។ នៅពេលដំបូង ជនរងគ្រោះបានប្រាប់នគរបាលថ្នាក់ស្រុក និងមេបញ្ជាការរបស់ឪពុកនាងអំពីការប៉ុនប៉ងរំលោភ។ ជាជាងអនុញ្ញាតឲ្យនគរបាលចាប់ខ្លួនជនសង្ស័យ មេបញ្ជាការរក្សាទុកគាត់នៅក្នុងបន្ទាយយោធា។ ជនរងគ្រោះបន្ទាប់មកបានទៅរកអង្គការលីកាដូសម្រាប់ជំនួយ ហើយអ្នកឃ្លាំមើលបានទៅស្នងការដ្ឋាននគរបាលខេត្ត ដើម្បីស្នើឲ្យមន្ត្រីនគរ-បាលទាំងនោះចាប់ខ្លួនជនសង្ស័យ។ទោះជាយ៉ាងណានៅពេលនោះមេបញ្ជាការបានអនុញ្ញាតឲ្យជនសង្ស័យរត់គេចខ្លួន។ ជនសង្ស័យនៅតែមិនទាន់ចាប់ខ្លួនបាន។

ក្មេងស្រីអាយុ ១៥ ឆ្នាំម្នាក់ត្រូវបានរំលោភសេពសន្ថវៈដោយអ្នកជិតខាងក្នុងយប់មួយ នៅពេលដែលនាងបានចាកចេញពីផ្ទះរបស់នាងដើម្បីទៅបង្គន់។ នៅពេលដែលនាង បានជូនដំណឹងទៅទីស្នាក់ការនគរបាល មូលដ្ឋានអំពីអ្វីដែលបានកើតឡើងចំពោះនាង នគរបាលបានប្រាប់ជនសង្ស័យថា ជនរងគ្រោះបានធ្វើការដាក់ពាក្យបណ្តឹងប្តឹងជនសង្ស័យ ហើយលុះត្រាតែជនសង្ស័យប្រគល់លុយឲ្យមន្ត្រីទាំងនោះ បើមិនដូច្នោះពួកគេនឹងចាប់ខ្លួនជនសង្ស័យ។ ជនសង្ស័យបានបង់ប្រាក់ឲ្យនគរបាល ហើយមន្ត្រីទាំងនោះបានអនុញ្ញាតឲ្យជននោះរត់គេចខ្លួន។ ករណីនេះកំពុងបន្តការជំនុំជម្រះក្តីតាមរយៈតុលាការ ប៉ុន្តែកន្លែងលាក់ខ្លួនរបស់ជនសង្ស័យនៅមិនទាន់រកឃើញ ។

ទូទៅ បានរាយការណ៍ថា មន្ត្រីនគរបាល និងមន្ត្រីតុលាការបានឆ្លើយតបនឹងការស្នើសុំព័ត៌មានថ្មីៗដោយនិយាយថាពួកគេនៅកំពុងតែធ្វើការស៊ើបអង្កេត ប៉ុន្តែតាមការពិតមិនមានភស្តុតាង ដែលបង្ហាញថាដំណើរការណាមួយត្រូវបានធ្វើឡើងនោះទេ។ ជាលទ្ធផល ករណីជាច្រើនជាធម្មតាមិនដែលឈានទៅដល់ដំណោះស្រាយណាមួយឡើយ។ នៅក្នុងករណីមួយចំនួនក្នុងចំណោមករណីខាងលើមូលហេតុ ដែលករណីនៅតែបន្តបើក ដោយគ្មានដំណោះស្រាយគឺថា ជនសង្ស័យបានរត់គេច ខ្លួនបាត់។ នៅក្នុងករណីចំនួន ៥២ ក្នុងចំណោមករណីចំនួន ៣៣០ ដែលត្រូវបានបើកនៅលើប្រព័ន្ធទិន្នន័យរបស់អង្គការលីកាដូ ព័ត៌មានថ្មីបំផុតគឺថាជនសង្ស័យបានរត់គេចខ្លួន។ ជាញឹកញាប់ អ្នកឃ្លាំមើលរបស់អង្គការលីកាដូមិនបានដឹងពី ព្រឹត្តការណ៍នៃការរត់គេចខ្លួនរបស់ជនល្មើសនោះទេ ប៉ុន្តែអ្នកទាំងនោះបានរាយការណ៍ថាជាធម្មតានេះជាលទ្ធផលនៃការខកខានរបស់នគរបាលក្នុងការឆ្លើយតបទៅនឹងការរាយការណ៍របស់ជនរងគ្រោះ។ នៅក្នុងករណីមួយចំនួនជនសង្ស័យត្រូវបានផ្តល់ដំណឹងដោយលួចលាក់ទុកជាមុនពីនគរបាលថា មានការដាក់ពាក្យបណ្តឹងប្តឹងទៅលើជនសង្ស័យ។ នៅក្នុងករណីមួយចំនួននៃករណីទាំងនេះ នគរបាលបានប្រើពាក្យបណ្តឹងរំលោភសេពសន្ថវៈធ្វើជាឱកាសមួយដើម្បីជំរិតទារប្រាក់ពីជនសង្ស័យ។ នៅក្នុងករណីផ្សេងទៀត ជនសង្ស័យត្រូវបានអនុញ្ញាតឲ្យរត់គេចខ្លួន ដោយសារតែពួកគេស្គាល់នគរបាល ឬជាអ្នកដែលមានអំណាច។

ជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈ ដែលមានអាយុក្រោម ១៨ ឆ្នាំ មានចំនួនខ្ពស់ បើធៀបទៅនឹងជនរងគ្រោះដែលមានអាយុ ១៨ ឆ្នាំ និងលើសពី ១៨ ឆ្នាំ។ ក្នុងចំណោមជនរងគ្រោះក្រោម ១៨ ឆ្នាំ ជនរងគ្រោះចំនួន ៥៨ នាក់ (១០%) គឺមានអាយុក្រោម ៦ ឆ្នាំ ចំនួន ១៨១ នាក់ (៣២%) គឺមានអាយុពី ៦ ទៅ ១១ ឆ្នាំ និងចំនួន ៣២៨ នាក់ (៥៨%) គឺមានអាយុពី ១២ ទៅ ១៧ ឆ្នាំ។[៤] តួលេខនេះមិនមែនមានន័យថា មានករណីរំលោភលើកុមារច្រើនជាងករណីរំលោភលើស្ត្រីពេញវ័យនោះទេ (ស្ត្រីពេញវ័យមានភាពស្ទាក់ស្ទើរច្រើនជាងក្នុងការធ្វើការរាយ-ការណ៍ ដោយការភ័យខ្លាចពីការស្តីបន្ទោស ឬមិនទទួលយកពីស្វាមីរបស់អ្នកទាំងនោះ និងគំនិតរើសអើងពីអ្នកជិតខាង)។ ដោយសារតែចំនួននៃករណីរំលោភលើកុមារ ដែលរួមទាំងការរំលោភលើកុមារអាយុក្រោម ១២ ឆ្នាំ គឺមានចំនួនខ្ពស់ នេះទាមទារឲ្យមានការយកចិត្តទុកដាក់ទៅលើ តម្រូវការសេវាកម្មនានានៅក្នុងប្រព័ន្ធតុលាការ ដែលត្រូវតែបង្កើតឡើងជាពិសេសដើម្បីបំពេញតាមតម្រូវការរបស់កុមារ។[៥]

ការពិនិត្យឡើងវិញលើករណីទាំងអស់ ដែលត្រូវបានបើកនៅក្នុងអំឡុងពេលនោះ ក៏បានចោទជាសំណួរអំពីករណីជាច្រើនដែលបានបាត់។ ក្នុងចំណោមករណីសរុប ៥៣៧ ករណី ដែលពាក់ព័ន្ធនិងកុមារ មានតែជនរងគ្រោះចំនួន ២៨ នាក់ ប៉ុណ្ណោះ ដែលជាក្មេងប្រុស។ ចំនួនទាបយ៉ាងខ្លាំងនេះស្ទើរតែ បានបង្ហាញយ៉ាងច្បាស់ថាជនរងគ្រោះជាភេទប្រុស មិនបានរាយការណ៍គ្រប់ករណីទាំងអស់នោះទេ ហើយប្រហែលជាមិនគួរឲ្យភ្ញាក់ផ្អើលនោះទេ ដោយសារគំនិតក្នុងសង្គមមិនបានគិតថាបុរសជាជនរងគ្រោះនៅក្នុងអំពើរំលោភសេពសន្ថវៈនោះទេ។ គំនិតនេះមិនអាចកាត់បន្ថយបាន ដោយតាមវិធីនៃការអនុវត្តច្បាប់របស់ប្រព័ន្ធតុលាការ

[៤] ចំនួនសរុបនៃជនរងគ្រោះគឺ ៥៦៧ នាក់ ដោយសារករណីមួយចំនួនពាក់ព័ន្ធនឹងជនរងគ្រោះច្រើនជាងម្នាក់។

[៥] សេចក្តីលម្អិតនៃការផ្តល់សេវាកម្មបែបនេះ គឺហួសពីវិសាលភាពនៃរបាយការណ៍នេះ ប៉ុន្តែត្រូវបានគ្របដណ្តប់យ៉ាងទូលំទូលាយនៅក្នុងរបាយការណ៍ថ្មី របស់អង្គការ Hagar/UNICEF។ Dr J.K. Reimer, A System Just for Children, January 2015 http://www.unicef.org/cambodia/A-System-Just-for-Children_FINAL_Jan-2015.pdf

ទៅលើជនរងគ្រោះដែលជាក្មេងប្រុសនោះទេ។ អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានរាយការណ៍ថា នគរបាលតែងតែមិនជឿចំពោះករណីក្មេងប្រុសដែលត្រូវបានរំលោភ ហើយមិនតែប៉ុណ្ណោះនគរបាលមួយចំនួន បានសើចចំអកដាក់ក្មេងប្រុសនៅពេលដែលកុមារទាំងនោះរៀបរាប់ពីបទពិសោធន៍របស់អ្នកទាំងនោះ។ នៅពេលដែលក្មេងប្រុសត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើការពិសោធន៍ ពីអំពើរំលោភសេពសន្ថវៈ វេជ្ជបណ្ឌិតមិនដឹងថាត្រូវពិនិត្យកុមារទាំងនោះដោយរបៀបណា។ ទោះជាករណីត្រូវបានបញ្ជូនទៅតុលាការក៏ដោយ ជារឿងធម្មតាសម្រាប់ព្រះរាជអាជ្ញានិងចៅក្រមក្នុងការចាត់ទុកថាករណីទាំងនេះជាអំពើប្រទូសកេរ្តិ៍ខ្មាស ដោយសារតែខ្វះខាតភស្តុតាងនៃការរំលោភសេពសន្ថវៈនៅក្នុងកោសល្យវិច័យពេទ្យនិងដោយសារតែព្រះ-រាជអាជ្ញា និងចៅក្រម ភាគច្រើនមិនជឿថាការចាប់រំលោភសេពសន្ថវៈលើបុរសអាចកើតមានឡើងនោះទេ។

ជាចុងក្រោយ នៅក្នុងករណីរំលោភសេពសន្ថវៈទាំងអស់ដែលត្រូវបានបើកនៅក្នុងអំឡុងពេលការសិក្សាស្រាវជ្រាវរយៈពេលបីឆ្នាំ មិនមានជនរងគ្រោះណាមួយត្រូវបានកត់ត្រាថាជាអ្នកបម្រើសេវាផ្លូវភេទនោះទេ។ ភ័ស្តុតាងដែលមានស្រាប់ បញ្ជាក់ថាអ្នកបម្រើសេវាផ្លូវភេទនៅទូទាំងពិភពលោក គឺជាអ្នកងាយរងគ្រោះខ្លាំងបំផុតទៅនឹងអំពើចាប់រំលោភសេពសន្ថវៈ។[៦] ការសិក្សាមួយនៅឆ្នាំ ២០១០ ស្តីពីការរំលោភសេពសន្ថវៈក្នុងប្រទេសកម្ពុជា ដោយអង្គការលើកលែងទោសអន្តរជាតិ ក៏មានភស្តុតាងដែលថា ការចាប់រំលោភលើអ្នកបម្រើសេវាផ្លូវភេទ គឺមានកំរិតខ្ពស់ ប៉ុន្តែកម្រិតនៃការរាយការណ៍ពីអំពើរំលោភនោះ គឺមានកម្រិតទាបខ្លាំងណាស់។[៧] ការសិក្សានេះរកឃើញថាហេតុផលមួយនៃការរាយការណ៍ គឺដោយសារមានការភ័យខ្លាចនៃអំពើហិង្សាបន្ថែមទៀត ឬ ការរំលោភសេពសន្ថវៈនៅក្នុងដៃរបស់នគរបាល។ ដោយសារអ្នកបម្រើសេវាផ្លូវភេទមួយចំនួនបានលាក់ទុកព័ត៌មានអំពីការងាររបស់អ្នកទាំងនោះពីអង្គការ លីកាដូ ដូចនេះយើងមិនអាចទទួលបានព័ត៌មានច្រើននោះទេ។ ចំនួនសរុបនៃករណីពាក់ព័ន្ធនឹងអ្នកបម្រើសេវាផ្លូវភេទដែលមិនអាចទទួលបាន ដោយផ្អែកលើទិន្នន័យពីប្រព័ន្ធទិន្នន័យរបស់អង្គការលីកាដូ បង្ហាញថាអ្នកទាំងនោះនៅមានភាពស្ទាក់ស្ទើរជាខ្លាំងក្នុងការរាយការណ៍ (សូម្បីតែធ្វើការរាយការណ៍ទៅអង្គការមិនមែនរដ្ឋាភិបាល) និងបង្ហាញថាក្រុមដែលងាយរងគ្រោះបំផុត គឺទទួលបានសេវាកម្មតិចតួចពីប្រព័ន្ធតុលាការ។



នគរបាលស្រាវជ្រាវករណីរំលោភកំពុងប្រមូលភស្តុតាង

[៦] Shannon et al, A systematic review of the correlates of violence against sex workers, American Journal of Public Health, May 2014, Volume 104(5), e42-54, http://www.ncbi.nlm.nih.gov/pubmed/24625169.

[៧] Amnesty International, Breaking the Silence – Sexual Violence In Cambodia, 2010, p.18 http://menengage.org/wp-content/uploads/2014/06/Breaking_the_silence_-_Sexual_violence_in_Cambodia_FINAL.pdf.



នគរបាលទៅផ្ទះជនរងគ្រោះដោយករណីរំលោភសេពសន្ថវៈ

## ប្រភេទនៃករណីដែលត្រូវបិទ

ការវិភាគលើករណីដែលត្រូវបានបិទ រួមមានជាដំបូងគឺការចែកករណីទៅជាបីប្រភេទធំៗ៖ ទីមួយ គឺករណី ដែលបានបញ្ចប់ជាមួយនឹងការកាត់ទោសចំពោះការរំលោភសេពសន្ថវៈ និងការកាត់ទោសឲ្យជាប់ពន្ធនាគារ ដោយគោរពទៅតាមលក្ខខណ្ឌនៃក្រមព្រហ្មទណ្ឌ។[៨] ទីពីរ គឺករណីដែលបានបញ្ចប់នៅចំណុចណាមួយមុនពេលការជំនុំជម្រះក្តី។ និងទីបី គឺករណីដែលបានធ្វើការជំនុំជម្រះក្តី ប៉ុន្តែត្រូវបានបញ្ចប់ដោយគ្មានការផ្តន្ទាទោសណាមួយ ឬ ជាមួយនិងការផ្តន្ទាទោសដែលគួរឲ្យសង្ស័យ។ របាយការណ៍នេះនឹងមើលលម្អិតទៅលើករណីដែលនៅក្នុងប្រភេទករណីពីរចុងក្រោយ ។

ប្រភេទករណីទីពីរ រួមមានករណីដែលបានបញ្ចប់ជាមួយនិងការផ្តល់សំណងពីជនសង្ស័យ ទៅកាន់ជនរងគ្រោះ ករណីដែលបានបញ្ចប់ជាមួយនិងការរៀបអាពាហ៍ពិពាហ៍រវាងជនសង្ស័យ និងជនរងគ្រោះ ករណីរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ ហើយនិងករណី ដែលជនរងគ្រោះដកពាក្យបណ្តឹងព្រហ្មទណ្ឌ ឧទាហរណ៍ដូចជា ដោយសារជនសង្ស័យនោះគឺជាសាច់ញាតិ ឬ ជាជនដែលមានអំណាច និងឥទ្ធិពលម្នាក់។

ប្រភេទករណីទីបី រួមមាន ករណីដែលមានការផ្តន្ទាទោស ប៉ុន្តែទោសត្រូវបានព្យួរទាំងស្រុង ឬ ត្រូវបានព្យួរមួយផ្នែក ករណីដែលជនល្មើសត្រូវបានផ្តន្ទាទោស ចំពោះបទល្មើសប្រទូសរ៉ាយខ្នាតស្រាលជំនួសឲ្យបទល្មើសរំលោភសេពសន្ថវៈ និងករណីដែលមានការផ្តន្ទាទោស ប៉ុន្តែការដាក់ទោសមានរយៈពេលខ្លីជាងការចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ ប្រភេទករណីនេះក៏មានរួមបញ្ចូលករណីមួយចំនួនតូច ដែលជនសង្ស័យត្រូវបានរកឃើញថាគ្មានកំហុស។ ក្នុងចំណោមករណីទាំងនេះ មិនមានភស្តុតាងច្បាស់លាស់បង្ហាញថាការសម្រេចសេចក្តីមានកំហុសនោះទេ ប៉ុន្តែចំពោះករណីមួយចំនួន គឺនៅក្នុងស្ថានភាពមួយដែលអ្នកឃ្លាំមើលរបស់អង្គការលីកាដូ មានអារម្មណ៍ថាការរកឃើញថាគ្មានកំហុស ដោយសារប្រហែលជាលទ្ធផលនៃអំពើពុករលួយនោះទេ។

[៨] មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកំណត់នូវធាតុផ្សំនៃបទរំលោភសេពសន្ថវៈ និងបានចែងថាបទល្មើសនេះគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលពី ៥ ឆ្នាំទៅ ១០ ឆ្នាំ។ មាត្រា ២៤០ ដល់ ២៤៤ កំណត់នូវបញ្ជីស្ថានទម្ងន់ទោសនៃការចោទប្រកាន់នៃការរំលោភសេពសន្ថវៈ។ អត្ថបទទាំងនេះបានបញ្ជាក់ថា ស្ថានទម្ងន់ទោសនៃបទល្មើសនេះគឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៧ ឆ្នាំទៅ ១៥ ឆ្នាំ។

ការសម្រេចសេចក្តីអំពីថា តើករណីណាមួយធ្លាក់ចូលទៅក្នុងប្រភេទទីមួយ ឬ ទីបីនោះគឺ ថាតើការផ្តន្ទាទោស និងការដាក់ពន្ធនាគារសមស្របឬមិនសមស្រប និងដោយផ្អែកលើព័ត៌មានអំពីអង្គហេតុនៃសំណុំរឿង ដែលត្រូវបានប្រមូលក្នុងអំឡុងពេលនៃការស៊ើបអង្កេតដោយអ្នកឃ្លាំមើលរបស់អង្គការ លីកាដូ។ វាប្រហែលជាមានហេតុផលស្របច្បាប់ (ដែលអង្គការលីកាដូមិនបានដឹង) ដែលឈានទៅដល់ការសម្រេចចិត្តរបស់សហចៅក្រម ប៉ុន្តែទោះជាយ៉ាងណា នៅក្នុងករណីជាច្រើន អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានចូលរួមក្នុងការជំនុំជម្រះក្តី និងបានមើលឃើញថាគ្មានហេតុផលបែបនេះទេ។

## លទ្ធផលនៃករណីទាំងអស់ដែលត្រូវបានបិទ

### លទ្ធផលនៃករណីនៃការរំលោភសេពសន្ថវៈពាក់ព័ន្ធនិងស្ត្រី និងកុមារ របស់អង្គការ លីកាដូ ពីឆ្នាំ២០១២ ដល់២០១៤ ដែលត្រូវបានបិទ

ក្នុងចំណោមករណីដែលត្រូវបានបិទ សរុប ៤២៤ ករណី ពាក់ព័ន្ធនិងស្ត្រី និងកុមារ មាន ១៤៧ (៣៥%) ករណី បានបញ្ចប់ជាមួយនិងការកាត់ទោសនិងការផ្តន្ទាទោសពន្ធនាគារសមស្រប ១៣៦ (៣២%) ករណី បានបញ្ចប់មុនពេលបើកសវនាការជំនុំជម្រះក្តី ហើយនិង ១៤១ (៣៣%) ករណី បានបញ្ចប់ជាមួយនឹងការជំនុំជម្រះក្តី ប៉ុន្តែមានការផ្តន្ទាទោសមិនត្រឹមត្រូវ ឬការសម្រេចឲ្យដោះលែង។




មុនពេលធ្វើការវិភាគលទ្ធផលទាំងនេះបន្ថែមទៀត វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា លទ្ធផលដែលបានកត់ត្រាដោយអង្គការលីកាដូ ទំនងជាមានផលវិជ្ជមានច្រើនជាងលទ្ធផលនៃករណីរំលោភសេពសន្ថវៈទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ជនរងគ្រោះជាច្រើនមិនបានរាយការណ៍ទាល់តែសោះ ហើយចំពោះអ្នកដែលបានរាយការណ៍ អ្នកទាំងនោះភាគច្រើនមិនមានការជួយគាំទ្រណាមួយឡើយ។ នៅពេលដែលអង្គការលីកាដូ (ឬអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត) បានចូលរួមពាក់ព័ន្ធ និងអាចជួយជនរងគ្រោះនិងជំរុញឲ្យនគរបាល និងតុលាការដើម្បីបន្តរឿងក្តីនោះ ឱកាសនៃការសម្រេចបាននូវលទ្ធផលជាទីពេញចិត្ត គឺមានកម្រិតខ្ពស់ជាងមុន។ ឧទាហរណ៍ ជាញឹកញាប់ដើមបណ្តឹងរបស់អង្គការ លីកាដូ បានរាយការណ៍ថា មុនពេលដែលអង្គការបានចូលរួមពាក់ព័ន្ធនៅក្នុងរឿងក្តីរបស់អ្នកទាំងនោះ នគរបាលគ្មានឆន្ទៈក្នុងការជួយដល់ពួកគាត់ ឬបានធ្វើការទាមទារឲ្យពួកគាត់បង់ប្រាក់ ដើម្បីស៊ើបអង្កេតរឿងក្តីរបស់អ្នកទាំងនោះ។ ប្រសិនបើអ្នកទាំងនោះយករឿងក្តីនេះទៅតុលាការ នោះមន្ត្រីតុលាការក៏ទាមទារឲ្យមានការបង់ប្រាក់ខុសច្បាប់មុននឹងពួកគេចាត់វិធានការណាមួយ។ នៅពេលដែលអង្គការលីកាដូបានចូលរួមពាក់ព័ន្ធ ផ្ទុយទៅវិញនគរបាល និងមន្ត្រីតុលាការតែងតែផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកទាំងនោះ និងយ៉ាងតិចណាស់មន្ត្រីទាំងនោះមិនទាមទារឲ្យមានការបង់ប្រាក់ទៀតទេ។ ដើមបណ្តឹងជាច្រើនបានរាយការណ៍ថា ប្រសិនបើអង្គការ លីកាដូ មិនបានចូលរួមពាក់ព័ន្ធនៅក្នុងរឿងក្តីរបស់អ្នកទាំងនោះទេ នោះពួកគាត់ប្រហែលជាលះបង់ចោលរឿងក្តីបាត់ទៅហើយ។

## ភាពខុសគ្នារវាងករណីដែលជាប់ពាក់ព័ន្ធនឹងស្ត្រី និងកុមារ

នៅពេលដែលលទ្ធផលនៃករណីដែលពាក់ព័ន្ធនឹងស្ត្រីអាយុ ១៨ឆ្នាំ និងលើសពី ១៨ឆ្នាំ និង កុមារអាយុក្រោម ១៨ឆ្នាំ ត្រូវបានវិភាគដោយឡែកពីគ្នា ភាពខុសគ្នាដែលគួរឲ្យចាប់អារម្មណ៍មួយចំនួនបានលេចឡើង។

### លទ្ធផលនៃករណីនៃការរំលោភសេពសន្ថវៈពាក់ព័ន្ធនិងស្ត្រីដែលមានអាយុ ១៨ឆ្នាំ និង លើសពី ១៨ឆ្នាំ របស់អង្គការលីកាដូ ពីឆ្នាំ២០១២ ដល់២០១៤




នៅក្នុងករណីដែលពាក់ព័ន្ធនឹងស្ត្រី ការបែងចែករវាង ប្រភេទទាំងបីខាងលើ គឺ៖ ៣១ ករណី ក្នុងចំណោមករណីសរុបចំនួន ១៣១ ករណី (២៣.៥%) បានបញ្ចប់ជាមួយនឹងការកាត់ទោសនិងការផ្តន្ទាទោសសមស្រប ៦៩ ករណី ក្នុងចំណោមករណីសរុបចំនួន ១៣១ ករណី (៥៣%) បានបញ្ចប់មុនពេលជំនុំជម្រះក្តី និង ៣១ ករណី ក្នុងចំណោមករណីសរុបចំនួន ១៣១ ករណី (២៣.៥%) បានបញ្ចប់ជាមួយនឹងការជំនុំជម្រះក្តីដែលមានភាពខ្វះចន្លោះ ឬ គ្មានការផ្តន្ទាទោស។

## លទ្ធផលនៃករណីនៃការរំលោភសេពសន្ថវៈពាក់ព័ន្ធកុមារដែលមានអាយុក្រោម ១៨ឆ្នាំ របស់អង្គការលីកាដូ ពីឆ្នាំ២០១២ ដល់២០១៤

នៅក្នុងករណីសិទ្ធិកុមារមាន ១១៦ ករណី ក្នុងចំណោមករណីសរុបចំនួន ២៩៣ ករណី (៣៩.៥%) ត្រូវបានបញ្ចប់ជាមួយនឹងការកាត់ទោសនិងការផ្តន្ទាទោសសមស្រប ៦៧ ករណី ក្នុងចំណោមករណីសរុបចំនួន ២៩៣ ករណី (២៣%) ត្រូវបានបញ្ចប់មុនពេលបើកសវនាការជំនុំជម្រះក្តី និង ១១០ ក្នុងចំណោមករណីសរុបចំនួន ២៩៣ ករណី (៣៧.៥%) ត្រូវបានបញ្ចប់ជាមួយនឹងកាជំនុំជម្រះក្តីដែលមានការផ្តន្ទាទោសមិនត្រឹមត្រូវ ឬ ការដោះលែងដោយគ្មានទោស។




ករណីដែលពាក់ព័ន្ធនឹងកុមារ មានភាគរយខ្ពស់នៅក្នុងលទ្ធផលនៃករណីប្រភេទទីមួយ គឺលទ្ធផលដែលមានការកាត់ទោសពីបទល្មើសរំលោភសេពសន្ថវៈ និងការផ្តន្ទាទោសសមស្រប (៣៩.៥% បើប្រៀបធៀបទៅនឹង ២៣.៥%)។ ចំនួនករណីជាច្រើនដែលពាក់ព័ន្ធនឹងស្ត្រីពេញវ័យ គឺមាននៅក្នុងប្រភេទករណីទីពីរករណីដែលជាករណីមិនបានឈានទៅដល់ការជំនុំជម្រះក្តី (៥៣% បើធៀបទៅនឹង ២៣%) ។

ហេតុផលសម្រាប់បញ្ហានេះ គឺទំនងជាមានការស្មុគស្មាញ ប៉ុន្តែវាអាចកើតឡើងយ៉ាងតិចណាស់មួយចំណែក ចេញពីការរំពឹងទុករបស់សង្គមទៅលើឥរិយាបទរបស់ស្ត្រី។ អ្នកឃ្លាំមើលរបស់អង្គការលីកាដូ បានរាយការណ៍ថា នៅពេលដែលជនរងគ្រោះត្រូវបានសាកសួរដោយនគរបាល ឬមន្ត្រីតុលាការ ឥរិយាបថរបស់ស្ត្រីពេញវ័យ ជាញឹកញាប់ត្រូវបានពិនិត្យពិច័យ ដែលនេះបង្ហាញអំពីអាកប្បកិរិយាចង់បញ្ជាក់ថា នេះជាការទទួលខុសត្រូវរបស់ស្ត្រីទាំងនោះ ក្នុងការមិនត្រូវធ្វើអ្វីមួយដែលអាចនាំឲ្យពួកគាត់ស្ថិតនៅក្នុងហានិភ័យនៃការរំលោភសេពសន្ថវៈ។ កុមារក្មេងៗត្រូវបានចាត់ទុកថាមានការគ្រប់គ្រងលើខ្លួនឯងបានតិចតួច ដូច្នេះគឺទំនងជាមិនត្រូវបានបន្ទោសចំពោះឥរិយាបថរបស់កុមារទាំងនោះនោះទេ។ នៅពេលដែលស្ត្រីត្រូវបានទទួលរងនូវការចោទសួរសំនួរបែបនេះ ជាមួយនឹងការបន្ទោសទៅលើពួកគាត់ នោះធ្វើឲ្យស្ត្រីទាំងនោះទំនងជានឹងមិនចង់បន្តរឿងក្តីនេះដល់ទីបញ្ចប់នោះទេ។ លើសពីនេះទៅទៀត អាចប្រហែលជា ប្រសិនបើចៅក្រមទទួលយកឥរិយាបទដូចដែលបានរៀបរាប់ខាងលើថា ស្ត្រីគឺមានកំហុសណាមួយដែលធ្វើឲ្យអ្នកទាំងនោះត្រូវបានគេចាប់រំលោភ នោះចៅក្រមគឺទំនងជាមិនធ្វើការផ្តន្ទាទោសណាមួយឡើយ។

បញ្ហានេះក៏មានមូលហេតុទីពីរដែរ។ ជាមូលហេតុជាក់ស្តែងដែលហេតុអ្វីបានជាករណីដែលពាក់ព័ន្ធនឹងស្ត្រីពេញវ័យ ត្រូវបានបញ្ចប់មុនពេលការជំនុំជម្រះក្តី។ ដូចដែលនឹងត្រូវបានបកស្រាយដូចខាងក្រោមនេះ ករណីបែបនេះជាច្រើនត្រូវបានបញ្ចប់ដោយការបង់ប្រាក់សំណងពីជនសង្ស័យទៅឲ្យជនរងគ្រោះ ដើម្បីធ្វើជាថ្នូរឲ្យជនរងគ្រោះដកពាក្យបណ្តឹង។ ការបង់ប្រាក់ទាំងនេះជាញឹកញាប់ត្រូវបានចរចារដោយនគរបាល ព្រះរាជអាជ្ញា ឬចៅក្រម ហើយបន្ទាប់ពីជនរងគ្រោះបានដកពាក្យបណ្តឹង មន្ត្រីដែលពាក់ព័ន្ធនឹងធ្វើការបិទសំណុំរឿងព្រហ្មទណ្ឌ។ នៅពេលដែលជនរងគ្រោះមានអាយុច្រើនជាង ១៥ ឆ្នាំ (អាយុស្របច្បាប់នៃការយល់ព្រមរួមភេទ) នោះជាការងាយស្រួលសម្រាប់នគរបាល និងមន្ត្រីតុលាការក្នុងការបញ្ចប់សំណុំរឿងព្រហ្មទណ្ឌ ដោយបញ្ជាក់ថាជនរងគ្រោះបានសារភាពថា ពួកគេបានយល់ព្រមរួមភេទ ហើយដូច្នេះជនសង្ស័យមិនមានរឿងក្តីដែលត្រូវឆ្លើយតបនោះទេ។ ប៉ុន្តែប្រសិនបើជនរងគ្រោះមានអាយុក្រោម ១៥ ឆ្នាំ បើយោងតាមច្បាប់ នាងមិនមានសមត្ថភាពក្នុងការផ្តល់ការយល់ព្រមរួមភេទនោះទេ ហើយមានការលំបាកខ្លាំងសម្រាប់នគរបាល និងមន្ត្រីតុលាការ ក្នុងការស្វែងរកហេតុផលដើម្បីបញ្ចប់សំណុំរឿងព្រហ្មទណ្ឌ។

## ភាពគ្មានឆន្ទៈដើម្បីធ្វើការរាយការណ៍

ក្មេងស្រីអាយុ ១១ ឆ្នាំម្នាក់ត្រូវបានរំលោភសេពសន្ថវៈដោយអ្នកជិតខាងអាយុ ៥៤ ឆ្នាំ ។ បុរសនោះបានគំរាមថាគាត់នឹងសម្លាប់នាង ប្រសិនបើនាងនិយាយប្រាប់នរណាម្នាក់អំពីអ្វីដែលគាត់បានប្រព្រឹត្ត។ ក្រុមគ្រួសាររបស់ក្មេងស្រីបានដឹងពីអ្វីដែលបានកើតឡើងចំពោះនាង ប៉ុន្តែបានសម្រេចចិត្តមិនធ្វើសកម្មភាពអ្វីទេ។អង្គការលីកាដូបានទទួលបានដំណឹងអំពីករណីនេះមកពីប្រភពផ្សេងទៀត និងបានធ្វើការទាក់ទងទៅក្រុមគ្រួសារដើម្បីសាកសួរថា អ្នកទាំងនោះចង់បានការគាំទ្រណាមួយដែរឬទេ។ ក្រុមគ្រួសារបាននិយាយថាពួកគាត់មិនចង់ធ្វើអ្វីនោះទេ ពីព្រោះពួកគាត់គ្មានជំនឿទាល់តែសោះចំពោះដំណើរការផ្លូវច្បាប់។ លើសពីនេះទៅទៀត ពួកគាត់មានការព្រួយបារម្ភថា ជនសង្ស័យនឹងធ្វើការសងសឹកប្រសិនបើពួកគាត់រាយការណ៍ និងដោយសារពួកគាត់រស់នៅទីជនបទឆ្ងាយពីនគរបាល គ្មាននរណាម្នាក់នឹងមកជួយពួកគាត់នោះទេ។ ពួកគាត់បាននិយាយថាស្ថានភាពហិរញ្ញវត្ថុរបស់ពួកគាត់គឺសមរម្យគ្រប់គ្រាន់ហើយ ដូច្នេះពួកគាត់មិនចង់ធ្វើការដាក់ពាក្យបណ្តឹងទាមទារសំណងនោះទេ។



ជើងរបស់កុមារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ

# អំពើពុករលួយ

ខាងក្រោមនេះ ប្រភេទនៃករណីជាច្រើនដែលត្រូវបានបញ្ចប់មុនពេលជំនុំជម្រះក្តី និងប្រភេទនៃករណីជាច្រើនដែលត្រូវបានបញ្ចប់ដោយការផ្តន្ទាទោសមិនត្រឹមត្រូវ ឬការសម្រេចដោះលែងដោយគ្មាន ទោស នឹងត្រូវបានពិនិត្យយ៉ាងលម្អិតបន្ថែមទៀត។ ប្រភេទនៃករណី នីមួយៗទាំងនេះ គ្របដណ្តប់ករណីដែលត្រូវបានបញ្ចប់ដោយវិធី សាស្ត្រមួយចំនួន និងដោយហេតុផលខុសៗប្លែកពីគ្នា។ ទោះបីជាមាន ភាពខុសៗគ្នាក៏ដោយ ក៏នៅមានចំនុចរួមមួយ ដែលមាននៅគ្រប់ប្រភេទនៃលទ្ធផលរបស់ករណីជាច្រើនគឺ៖ អំពើពុករលួយ។ ពីករណីដែលត្រូវបានបញ្ចប់ជាមួយនឹងការព្រមព្រៀងផ្តល់សំណង នៅទីស្នាក់ការនគរបាលមូលដ្ឋាន រហូតទៅដល់ករណីដែលឈានទៅដល់ការជំនុំជម្រះក្តី នៅក្នុងករណីទាំងនេះ អំពើពុករលួយ គឺជាធាតុផ្សំពិសេសមួយ។

ចំនួនករណីជាច្រើនដែលអង្គការលីកាដូ មានព័ត៌មានច្បាស់លាស់អំពីការបង់ប្រាក់ពុករលួយទៅដល់មន្ត្រី គឺមានចំនួនតិច។ មានហេតុផលជាច្រើនចំពោះបញ្ហានេះគឺ៖ នៅក្នុងករណីជាច្រើន ជនរងគ្រោះមិនបានដឹងអ្វីសោះអំពីបញ្ហានេះ ដោយសារការចរចា និងការបង់ប្រាក់ត្រូវបានធ្វើឡើងជាលក្ខណៈឯកជនរវាងជនសង្ស័យ និងមន្ត្រីសាធារណៈ។ ក្នុងករណីផ្សេងទៀត ជនរងគ្រោះបានចូលរួមពាក់ព័ន្ធនៅក្នុងការចរចានេះ ប៉ុន្តែអ្នកចរចាបានឲ្យជនរងគ្រោះធ្វើការស្បថដោយលាក់អាថ៌កំបាំងនេះ និងបានប្រាប់ជនរងគ្រោះថាអ្នកទាំងនោះនឹងត្រូវបានផ្តន្ទាទោសប្រសិនបើពួកគាត់បញ្ចេញព័ត៌មាននេះ។[៩] ចំពោះជនរងគ្រោះដែលជាកូនក្តីរបស់អង្គការលីកាដូ ជារឿងទូទៅ សម្រាប់អ្នកចរចាក្នុងការព្រមានជនរងគ្រោះ មិនឲ្យនិយាយប្រាប់អង្គការ លីកាដូ។

បើទោះបីជាយ៉ាងនេះក៏ដោយ អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ ដែលមួយចំនួនមានបទពិសោធន៍ ២០ ឆ្នាំ នៅក្នុងវិស័យនេះ ជាញឹកញាប់បានទទួលព័ត៌មានអំពីអំពើពុករលួយពីជនរងគ្រោះ និងប្រភពផ្សេងទៀតនៅតុលាការ ឬនៅកន្លែងផ្សេង។ អ្នកឃ្លាំមើលទាំងនោះបានបញ្ជាក់ថានៅក្នុងបទពិសោធន៍របស់អ្នកទាំងនោះ អំពើពុករលួយ គឺមានច្រើនសន្ធឹកសន្ធាប់ ហើយនៅគ្រប់ដំណាក់កាលនៃរឿងក្តីដែលមានទំនាក់ទំនងរវាងជនរងគ្រោះនិងមន្ត្រីសាធារណៈ គឺអាចមានឱកាស ដែលអាចមានអំពើពុករលួយប្រភេទណាមួយអាចនឹងកើតមានឡើង។

ដោយសារតែចរិកលក្ខណៈ ដែលអាចកើតមាននៅស្ទើរគ្រប់ទីកន្លែង អំពើពុករលួយ នឹងមិនត្រូវបានចាត់ទុកថាជាប្រធានបទមួយដាច់ដោយឡែកនៅក្នុងរបាយការណ៍នេះទេ។ ដូច្នេះនៅក្នុងលទ្ធផលនៃប្រភេទករណីផ្សេងៗនីមួយៗ ដែលនឹងត្រូវបានពិនិត្យដោយឡែកពីគ្នា នឹងត្រូវរួមបញ្ចូលតួនាទីរបស់អំពើពុករលួយផងដែរ។ ករណីមួយចំនួន ដែលអ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានទទួលព័ត៌មាន ច្បាស់លាស់ ត្រូវបានបង្ហាញដូចខាងក្រោម និងការសន្និដ្ឋានអំពីវិសាលភាព ចរិកលក្ខណៈ និងផលប៉ះពាល់នៃអំពើពុករលួយ ត្រូវបានទាញចេញពីករណីទាំងអស់នោះ និងពីបទពិសោធន៍ដ៏ទូលំទូលាយ របស់អ្នកឃ្លាំមើល។



ប៉ុស្តិ៍នគរបាល

[៩] នេះមិនមែនជាការគម្រាមកំហែងលេងសើចមួយទេ។ នៅក្នុងមាត្រា ៦០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ ២០០៩) ការផ្តល់សំណូកទៅកាន់មន្ត្រីសាធារណៈ គឺត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ។



អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ សម្ភាសន៍កុមារីរងគ្រោះដោយអំពីរំលោភសេពសន្ថវៈ

# ការបញ្ចប់រឿងក្ដីដោយសំណង

ចំនួនជាច្រើននៃករណី ដែលចូលនៅក្នុងប្រភេទករណីដែលត្រូវបានបញ្ចប់មុនពេលឈានទៅដល់ការជំនុំជម្រះក្ដី គឺជាករណីដែលត្រូវបានបញ្ចប់រឿងក្ដីដោយសំណង។ នៅក្នុង ៧២ ករណី ក្នុងចំណោម ៤២៤ ករណីដែលត្រូវបានបិទ (១៧%) ជនរងគ្រោះបានទទួលការបង់ប្រាក់សំណងពីជនសង្ស័យ ដើម្បីធ្វើជាថ្នូរក្នុងការដកពាក្យបណ្ដឹង។ ៣៦ ករណីដែលពាក់ព័ន្ធនឹង ស្ត្រីអាយុ ១៨ ឬ លើសពី ១៨ ឆ្នាំ (២៧% នៃចំនួនករណីសរុប ១៣១ ករណីដែលពាក់ព័ន្ធនឹងស្ត្រី) និង ៣៦ ករណីដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ ឆ្នាំ (១២% នៃ ២៩៣ ករណីដែលពាក់ព័ន្ធនឹងកុមារ)។ ក្រលេកទៅមើលករណីដែលពាក់ព័ន្ធនឹងស្ត្រីនិងកុមាររួមគ្នា ក្នុងចំណោម ៧២ ករណីដែលត្រូវបានបញ្ចប់រឿងក្ដីដោយសំណង ៤៣ ករណីត្រូវបានចរចារដោយនគរបាល (នគរបាលគ្រប់ប្រភេទដែលមានការជាប់ពាក់ព័ន្ធរួមមានថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថែមទាំងនគរបាលប្រឆាំងការជួញដូរមនុស្សទៀតផង)។ នៅក្នុងករណីខ្លះ ជនរងគ្រោះខ្លួនឯងផ្ទាល់បានបញ្ជាក់ពីដំបូងថា ពួកគាត់ចង់ចរចារកដំណោះស្រាយសំណង និងមិនចង់ទៅតុលាការ ប៉ុន្តែជារឿងធម្មតាច្រើនជាងដែលនគរបាលជាអ្នកផ្ដួចផ្ដើមការចរចារវាងជនរងគ្រោះ និងជនសង្ស័យ។

ករណីតិចតួចណាស់ ដែលត្រូវបានចរចារនៅក្នុងតុលាការជាចម្បងដោយសារតែប្រសិនបើនគរបាលគិតថាមានឱកាសក្នុងការបង់ប្រាក់សំណង ពួកគេនឹងរក្សាទុកករណីនេះរហូតដល់ការចរចារទទួលបានជោគជ័យ ប៉ុន្តែដោយសារតែមានការលំបាកខ្លាំងដើម្បីបិទរឿងក្ដីព្រហ្មទណ្ឌមួយ នៅពេលដែលរឿងនោះត្រូវបានបញ្ជូនទៅដល់តុលាការ។ ក្នុងចំណោម ៧២ ករណី អ្នកឃ្លាំមើលទទួលបានដំណឹងថា ៦ ករណី ត្រូវបានចរចារដោយព្រះរាជអាជ្ញា និង ៣ ករណីត្រូវបានចរចារដោយចៅក្រមស៊ើបអង្កេត។ ២០ ករណីដែលនៅសល់ត្រូវបានចរចារដោយគ្មានអន្តរការី ឬ មិនមានព័ត៌មានអំពីអ្នកដែលពាក់ព័ន្ធនៅក្នុងការចរចារ។

## ការបង់ប្រាក់ក្រៅច្បាប់ទៅឲ្យមន្ត្រីនានា

អ្នកឃ្លាំមើលទាំងអស់បាននិយាយថា ពួកគេជឿជាក់ថាស្ទើរតែ ១00% នៃករណីដែលបញ្ចប់រឿងក្ដីដោយសំណង គឺមានជាប់ពាក់ព័ន្ធនឹងការបង់ប្រាក់ក្រៅច្បាប់ទៅឲ្យមន្ត្រីពាក់ព័ន្ធ ដែលធ្វើឡើងដោយជនសង្ស័យ ឬដោយជនរងគ្រោះដោយធ្វើការកាត់ប្រាក់សំណងរបស់ជនរងគ្រោះទៅឲ្យមន្ត្រីពាក់ព័ន្ធ។ ព័ត៌មានអំពីបញ្ហានេះ គឺមានការលំបាកក្នុងការប្រមូល ដោយសារនគរបាល និងមន្ត្រីតុលាការ គឺមានភាពប៉ិនប្រសព្វយ៉ាងខ្លាំង ក្នុងការបំបាត់នូវភស្តុតាងលាយល័ក្ខអក្សរអំពីអំពើពុករលួយរបស់មន្ត្រីទាំងនោះ។ ជានិច្ចជាកាល អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានឃើញឯកសារដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ ពីការបង់ប្រាក់សំណងធ្វើឡើងដោយជនសង្ស័យជូនទៅជនរងគ្រោះ។ ឯកសារទាំងនោះមិនបានធ្វើការលើកឡើងពីករណីព្រហ្មទណ្ឌនោះទេ ហើយវាគ្រាន់តែបានបញ្ជាក់ថាមនុស្សម្នាក់បានយល់ព្រមបង់ប្រាក់ទៅមនុស្សម្នាក់ផ្សេងទៀត និងថាកិច្ចព្រមព្រៀងនេះត្រូវជាប់កាតព្វកិច្ចស្របច្បាប់។ នៅពេលដែលការផ្ដល់សំណងត្រូវបានចរចារដោយនគរបាល ជនរងគ្រោះក៏បានរាយ-ការណ៍ថា ពួកគាត់ត្រូវផ្ដិតមេដៃលើឯកសារដែលបានបញ្ជាក់ថាពួកគាត់បានដកពាក្យបណ្ដឹងព្រហ្មទណ្ឌប្ដឹងជនសង្ស័យ។ ចំពោះករណីដែលត្រូវបានចរចារនៅតុលាការ ជនរងគ្រោះមួយចំនួនបានរាយការណ៍ថា អ្នកទាំងនោះត្រូវចុះហត្ថលេខាលើសេចក្ដីថ្លែងការរបស់សាក្សីថ្មីមួយ ដោយសរសេរថាជនរងគ្រោះទាំងនោះបានយល់ព្រមនឹងការរួមភេទ ហើយដូច្នេះមិនត្រូវបានគេចាប់រំលោភសេព-សន្ថវៈនោះទេ។ ឯកសារនេះអនុញ្ញាតឲ្យព្រះរាជអាជ្ញា ឬចៅក្រម ធ្វើការបិទរឿងក្ដីដោយគ្មានបញ្ចប់ការជំនុំជម្រះក្ដី។

ទោះបីជាមានករណីដូចខាងលើ នៅក្នុងករណីមួយចំនួនតូច កូនក្តីជាច្រើនបានធ្វើការជូនដំណឹងដល់អ្នកឃ្លាំមើលរបស់អង្គការលីកាដូ ឬអ្នកឃ្លាំមើលអង្គការលីកាដូទទួលបានព័ត៌មានអំពីការបង់ប្រាក់ក្រៅច្បាប់ពីប្រភពផ្សេងទៀត។ នៅក្នុង ១១ ករណីដែលបានចរចាដោយនគរបាល អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានទទួលព័ត៌មានជាក់លាក់ថា នគរបាលបានទទួលប្រាក់ត្រឡប់មកវិញក្នុងការធ្វើជាឈ្មួញកណ្តាលក្នុងកិច្ចព្រមព្រៀងសំណងនេះ។ នៅករណីមួយក្នុងចំណោមករណីទាំងនេះ ជនសង្ស័យក៏បានបង់ប្រាក់ទៅឲ្យព្រះរាជអា ជ្ញាដើម្បីធានាថាគាត់នឹងមិនត្រូវបានចោទប្រកាន់។ នៅក្នុងករណីចំនួនពីរ ដែលព្រះរាជអាជ្ញាបានចរចារក្នុងកិច្ចព្រមព្រៀងសំណង ជនរងគ្រោះបានបញ្ជាក់ថាជនសង្ស័យក៏បានបង់ប្រាក់ទៅឲ្យព្រះរាជអាជ្ញាផងដែរ។ នៅក្នុងករណីពីរផ្សេងទៀត ដែលត្រូវបានចរចាររវាងភាគី អ្នកឃ្លាំមើលរបស់អង្គការលីកាដូបានទទួលព័ត៌មានថា ជនសង្ស័យបានបង់ប្រាក់ទៅឲ្យចៅក្រមស៊ើបអង្កេតដើម្បីលុបចោលរឿងក្តីរបស់ពួកគេ។

ព័ត៌មានអំពីចំនួនប្រាក់ដែលបានបង់ទៅឲ្យមន្ត្រី គឺមានកំរិត ប៉ុន្តែនៅក្នុងករណីមួយចំនួន ដែលនគរបាលបានធ្វើកាត់យកប្រាក់សំណងរបស់ជនរងគ្រោះ ជនរងគ្រោះបានជូនដំណឹងទៅឲ្យអ្នកឃ្លាំមើលរបស់អង្គការលីកាដូ។ បរិមាណប្រែប្រួលយ៉ាងទូលំទូលាយ។ នៅក្នុងករណីមួយដែល ជនរងគ្រោះបានរំពឹងថានឹងទទួលបាន ៥០០ ដុល្លារ នគរបាលបានដកយក ១៥ ដុល្លារ។ នៅក្នុងករណីមួយផ្សេងទៀត ជនសង្ស័យបានយល់ព្រមបង់ប្រាក់ឲ្យជនរងគ្រោះ ២៣០០ ដុល្លារ ប៉ុន្តែជនរងគ្រោះទទួលបានតែ ២១០០ ដុល្លារប៉ុណ្ណោះ ហើយនគរបាលរក្សាទុកប្រាក់ ២០០ ដុល្លារ ។ ក្នុងករណីពីរផ្សេងទៀតដែលជនរងគ្រោះរំពឹងថានឹងទទួលបាន ១២០០ ដុល្លារ និង ១៧៥០ ដុល្លារ បន្ថែមទៀត នគរបាលបានដកយក ៥០០ ដុល្លារ។ ក្នុងករណីចុងក្រោយមួយ ជនរងគ្រោះបានចរចារការបង់ប្រាក់ ៤០០០ ដុល្លារ ប៉ុន្តែនគរបាលបានបញ្ចុះបញ្ចូលឲ្យនាងយកត្រឹមតែ ២០០០ ដុល្លារ។ ជនរងគ្រោះបានប្រាប់អ្នកឃ្លាំមើលរបស់អង្គការលីកាដូថា នគរបាលបានរក្សាទុកប្រាក់ ២០០០ ដុល្លារផ្សេងទៀត។ ក្នុងអំឡុងពេលពីឆ្នាំ ២០១២ ដល់ ឆ្នាំ ២០១៤ អ្នកឃ្លាំមើលរបស់អង្គការលីកាដូ មិនទទួលបានព័ត៌មានណាមួយអំពីបរិមាណនៃការបង់ប្រាក់ជូនទៅព្រះរាជអាជ្ញា ឬចៅក្រម សម្រាប់ការចរចាកិច្ចព្រមព្រៀងសំណងនោះទេ។ ទោះជាយ៉ាងណា ដោយផ្អែកលើបទពិសោធន៍កន្លងមក មានការមូលមតិគ្នាមួយនៅក្នុងចំណោមអ្នកឃ្លាំមើលថា ចំនួនទឹកប្រាក់អប្បបរមាគឺ ៥០០ ដុល្លារ និងចំពោះជនសង្ស័យដែលជាអ្នកមាន ជាញឹកញាប់ចំនួនទឹកប្រាក់គឺរាប់ពាន់ដុល្លារ។

## ហេតុអ្វីបានជាជនរងគ្រោះយល់ព្រមបញ្ចប់រឿងក្តីដោយប្រាក់សំណង

ការបន្តរឿងក្តីព្រហ្មទណ្ឌតាមរយៈតុលាការ គឺជាទិដ្ឋភាពដែលមិនគួរឲ្យទាក់ទាញយ៉ាងខ្លាំង សម្រាប់ជនរងគ្រោះជាច្រើននាក់។ ហេតុផលមួយក្នុងចំណោមហេតុផលចម្បងជាច្រើនចំពោះបញ្ហានេះ គឺថាមានមនុស្សជាច្រើន នឹងបានដឹងលឺអំពីករណីនេះប្រសិនបើត្រូវបានបញ្ជូនទៅតុលាការ។ ការបញ្ចប់រឿងក្តីឲ្យបានឆាប់ និងនៅទីស្នាក់ការនគរបាល មានន័យថាជនរងគ្រោះនឹងមានឱកាសច្រើនក្នុងការរក្សាការសម្ងាត់នៃករណីនេះ។ សង្គមកម្ពុជា គឺជាសង្គមមួយដែលឲ្យតម្លៃខ្ពស់ណាស់ទៅលើសីលធម៌ផ្លូវភេទ និងព្រហ្មចារីរបស់ស្ត្រី ហើយការដាក់បន្ទុកលើស្ត្រីក្នុងការរក្សាគុណតម្លៃរបស់ខ្លួនទាំងនេះ គឺមានទំងំយ៉ាងធ្ងន់ធ្ងរ។ ការបាត់បង់ព្រហ្មចារី ទោះបីជាតាមរយៈការចាប់រំលោភក៏ដោយ ក៏អាចធ្វើឲ្យស្ត្រីក្លាយជាមនុស្សដែលមិនគួរឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយ នៅក្នុងកែវភ្នែករបស់អ្នកដែលនៅជុំវិញស្ត្រីទាំងនោះ។ ដូច្នេះមិនមែនមិនសមហេតុផលសម្រាប់ស្ត្រី និងក្មេងស្រី ដើម្បីចង់ធានាថាមនុស្សតិចតួចណាស់បានដឹងលឺថា អ្នកទាំងនោះត្រូវបានគេចាប់រំលោភនោះទេ។ ក្នុងករណីមួយចំនួន កូនក្តីរបស់អង្គការលីកាដូបានឲ្យដឹងថា អ្នកទាំងនោះមិនចង់ដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌនោះទេ ព្រោះជាពេលវេលាសម្រាប់អ្នកទាំងនោះដើម្បីរៀបអាពាហ៍ពិពាហ៍ ហើយពួកគេមិនចង់ឲ្យអ្នកណាម្នាក់ដឹងអំពីករណីនេះទេ។ ក្នុងករណីមួយ ជនរងគ្រោះបានធ្វើការដាក់ពាក្យបណ្តឹង ប៉ុន្តែក្រោយមកនៅពេលដែលនាងបានភ្ជាប់ពាក្យ នាងបានដកពាក្យបណ្តឹង ដោយសារតែនាងមិនចង់ឲ្យគូដណ្តឹងរបស់នាងដឹងថានាងត្រូវបានគេចាប់រំលោភ។

មូលហេតុសំខាន់ទីពីរ ដែលឈានដល់ការបញ្ចប់រឿងក្តីដោយការផ្តល់សំណង គឺការចំណាយ និងផលលំបាកជាក់ស្តែងក្នុងការបន្តរឿងក្តីតាមរយៈតុលាការ។ បញ្ហានេះមានទម្រង់ជាច្រើនប្រភេទ។ សម្រាប់កូនក្តីដែលក្រីក្រខ្លាំង ត្រឹមតែប្រាក់ចំណាយសម្រាប់ការធ្វើដំណើរទៅតុលាការទៅវិញទៅមកអាចធ្វើឲ្យការបន្តរឿងក្តីមានការលំបាក។ លើសពីនេះទៀត ប្រជាជនកម្ពុជាភាគច្រើនបានដឹងអំពីអំពើពុករលួយមួយចំនួនក្នុងប្រព័ន្ធតុលាការ និងបានដឹងថាទោះបីជាការពិត មិនមានការបង់ប្រាក់ណាមួយត្រូវបានទាមទារនៅក្នុងច្បាប់ក៏ដោយ ក៏ជនរងគ្រោះទំនងជាត្រូវធ្វើការបង់ប្រាក់ក្រៅផ្លូវការនៅគ្រប់ដំណាក់កាលនៃរឿងក្តី ប្រសិនបើអ្នកទាំងនោះចង់បន្តរឿងក្តី។ បន្ថែមពីនេះ ដូចដែលបានរៀបរាប់ខាងលើ ជាញឹកញាប់រឿងក្តីអាចបន្តរយៈពេលជាច្រើនឆ្នាំ ដើម្បីឈានដល់ការសន្និដ្ឋានមួយ ហើយនៅពេលណាដែលរឿងត្រូវបានអូសបន្លាយ កាន់តែយូរទៅនោះជនរងគ្រោះកាន់តែស្រងាកចិត្តយ៉ាងខ្លាំង ជាមួយនឹងដំណើរការផ្លូវច្បាប់ និងធ្វើការសម្រេចចិត្តថាពួកគេចង់បញ្ចប់រឿងក្តី។

ជនរងគ្រោះ ក៏មានការយល់ដឹងថា ឱកាសទទួលបានលទ្ធផលដែលពួកគេចង់បាន គឺមានតិចតួចណាស់។ ទីមួយ ប្រសិនបើជនសង្ស័យមានប្រាក់ នោះឱកាសដែលជនសង្ស័យនឹងត្រូវបានផ្តន្ទាទោសឲ្យបានត្រឹមត្រូវ គឺទំនងជាមិនអាចកើតមានឡើងទេ។ ទីពីរ បើទោះបីជាករណីនេះទទួលបានការជំនុំជម្រះក្តី ហើយជនសង្ស័យត្រូវបានជាប់ពន្ធនាគារ និងបង្គាប់ឲ្យបង់ប្រាក់សំណងរដ្ឋប្បវេណីក៏ដោយ ក៏យន្តការផ្លូវច្បាប់សម្រាប់អនុវត្តការបង់ប្រាក់សំណងមានភាពស្មុគស្មាញ និងតម្រូវឲ្យមានការបង់ប្រាក់ពុករលួយបន្ថែមទៀតទៅឲ្យតុលាការ ប្រសិនបើអ្នកទាំងនោះចង់មានឱកាសទទួលបានជោគជ័យណាមួយ។ នគរបាលបានដឹងច្បាស់លាស់អំពីបញ្ហា



## ថ្លៃចំណាយលើការបញ្ចប់រឿងក្តីដោយប្រាក់សំណង

ក្មេងស្រីអាយុ ៩ ឆ្នាំ ម្នាក់ត្រូវបានចាប់រំលោភសេពសន្ថវៈប្រាំដង ដោយអ្នកជិតខាងអាយុ ២៣ ឆ្នាំ។ គ្រួសារជនរងគ្រោះបានរាយការណ៍ពីករណីនេះ ទៅកាន់នគរបាលថ្នាក់ឃុំ ដែលជាអ្នកចរចារប្រាក់សំណងជាមួយជនសង្ស័យ។ គ្រួសារជនរងគ្រោះបានឯកភាពថា ពួកគេនឹងទទួលបានប្រាក់ ១២០០ ដុល្លារ និងដកពាក្យបណ្តឹងព្រហ្មទណ្ឌ។ ទីបំផុតនៅពេលដែលពួកគេបានទទួលប្រាក់ពីនគរបាល ពួកគេបានទទួលត្រឹមតែ ៧០០ ដុល្លារ ប៉ុណ្ណោះ។ នគរបាលបាននិយាយថា ពួកគេបានយកប្រាក់នោះជាការទូទាត់ប្រាក់សម្រាប់ការជួយសម្រួលដល់កិច្ចព្រមព្រៀង សម្រាប់ការចំណាយលើការដឹកជញ្ជូន និងសម្រាប់ការបង់ប្រាក់ទៅឲ្យនាយកដ្ឋាននគរបាល ដទៃទៀតដើម្បីធានាថាមន្ត្រីនគរបាលផ្សេងទៀតនឹងមិនធ្វើការស៊ើបអង្កេតអំពីករណីនេះ។ ពួកគាត់យល់ថាសមរម្យ គ្រប់គ្រាន់ហើយ ដូច្នេះពួកគាត់មិនចង់ធ្វើការដាក់ពាក្យបណ្តឹងទាមទារសំណងនោះទេ។

កុមារីរងគ្រោះដោយអំពីរំលោភសេពសន្ថវៈ

ទាំងអស់ខាងលើ ហើយជាញឹកញាប់បញ្ហាទាំងនេះត្រូវបានយកមកប្រើប្រាស់ដោយនគរបាល ក្នុងការបញ្ចុះបញ្ចូលជនរងគ្រោះឲ្យបញ្ចប់រឿងក្តី។ សម្រាប់ជនរងគ្រោះជាច្រើន ជាពិសេសអ្នកដែលក្រីក្រ ការបញ្ចប់រឿងក្តីនៅពេលដំបូង គឺជាការសម្រេចចិត្តសមហេតុផលដោយសារការបង់ប្រាក់សំណង គឺជាយុត្តិធម៌ល្អបំផុតដែលអ្នកទាំងនោះសង្ឃឹមថាអាចទទួលបាននៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។

កត្តាចុងក្រោយមួយ ដែលមានឥទ្ធិពលលើការសម្រេចចិត្តរបស់ជនរងគ្រោះអំពី ថាតើគួរបញ្ចប់រឿងក្តីដោយប្រាក់សំណងដែរឬទេនោះ គឺជាអំណាចនិងឥទ្ធិពលរបស់ជនសង្ស័យ។ មានករណីមួយចំនួនដែលក្នុងនោះជនសង្ស័យមានទ្រព្យសម្បត្តិ និងមានមិត្តភក្តិដែលមានអំណាច ឬធ្វើការឲ្យនគរបាល ឬយោធា។ ក្នុងករណីទាំងនេះ ជនរងគ្រោះអាចមានអារម្មណ៍ថាគាត់ត្រូវបានបង្ខំឲ្យបញ្ចប់រឿងក្តី ដោយការគំរាមកំហែងពីខាងក្រៅ ឬពីខាងក្នុង ដែលជនសង្ស័យអាចនឹងចាត់វិធានការសងសឹក ប្រសិនបើជនរងគ្រោះមិនធ្វើការបញ្ចប់រឿងក្តី។

ឧទាហរណ៍ ករណីចំនួនពីរដែលជនសង្ស័យ គឺជាមន្ត្រីនគរបាលម្នាក់ និងករណីមួយផ្សេងទៀតដែលជនសង្ស័យគឺជាកូនរបស់មន្ត្រីនគរបាល ត្រូវបានដោះស្រាយដោយបង់ប្រាក់សំណងដែលត្រូវបានចរចារដោយមន្ត្រីនគរបាលមួយផ្សេងទៀត។ នៅក្នុងករណីមួយក្នុងចំណោមករណីទាំងនេះ ការចរចារបានកើតឡើងនៅក្នុងទីស្នាក់ការនគរបាល ដែលជាកន្លែងដែលជនសង្ស័យធ្វើការហើយ ត្រូវបានសម្របសម្រួលដោយមិត្តរួមការងារ របស់ជនសង្ស័យ។ ទីស្នាក់ការនគរបាលមានទីតាំងស្ថិតនៅជិតនឹងផ្ទះរបស់ជនរងគ្រោះ។ បន្ទាប់ពីប្រាក់សំណងត្រូវបានបង់ សកម្មភាពតែមួយគត់ដែលត្រូវបានធ្វើឡើងចំពោះជនសង្ស័យ គឺផ្លាស់ប្តូរគាត់ទៅទីស្នាក់ការនគរបាលមួយផ្សេងទៀត។

ក្នុងករណីផ្សេងទៀត ជនរងគ្រោះ គឺជាក្មេងស្រីអាយុ ១២ឆ្នាំម្នាក់។ ឪពុករបស់នាង គឺជាទាហាន និងជនសង្ស័យ គឺជាមេបញ្ជាការរបស់គាត់។ ក្រុមគ្រួសារនេះរស់នៅលើដីជាប់នឹងបន្ទាយយោធា។ ដំបូង ក្រុមគ្រួសារបានយករឿងក្តីនេះទៅតុលាការ ប៉ុន្តែក្រោយមកបានធ្វើការដកពាក្យបណ្តឹង ដោយសារអ្នកទាំងនោះព្រួយបារម្ភថា ពួកគាត់នឹងបាត់បង់ដីរបស់ពួកគាត់ ហើយឪពុកអាចនឹងបាត់បង់ការងារ។ អ្នកឃ្លាំមើលនៅក្នុងករណីនេះគិតថា ក្រុមគ្រួសារជនរងគ្រោះទំនងជាទទួលបានសំណង។ ប៉ុន្តែនៅពេលដែលក្រុមគ្រួសារធ្វើការដកពាក្យបណ្តឹង មានផលលំបាកខ្លាំងណាស់ក្នុងការទទួលបានព័ត៌មានបន្ថែមពីអ្នកទាំងនោះ ហើយពួកគាត់អាចប្រហែលជាមិនទទួលបានសំណងអ្វីទាល់តែសោះ។

## ការបង់ប្រាក់សំណង និងច្បាប់

ច្បាប់កម្ពុជា អនុញ្ញាតឲ្យជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌដែលមានការរងរបួសផ្ទាល់ខ្លួន ធ្វើការដាក់ពាក្យបណ្តឹងសំរាប់សំណងការខូចខាត នៅពេលតែមួយក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងនេះជាពាក្យបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបញ្ចប់ដោយការបង់ប្រាក់សំណង (បណ្តឹងនេះតែងតែត្រូវបានដោះស្រាយដោយនគរបាល ដែលនេះមិនមែនជាការអនុវត្តតាមទ្រឹស្តីច្បាប់ដែលតម្រូវឲ្យដោះស្រាយសំណងរដ្ឋប្បវេណីក្រោយពេលជនរងគ្រោះបានដាក់ពាក្យបណ្តឹងណាមួយទៅតុលាការនោះទេ)។ ការដោះស្រាយពាក្យបណ្តឹងរដ្ឋប្បវេណី នៅខាងក្រៅប្រព័ន្ធតុលាការ គឺមិនមែនជាការខុសច្បាប់នោះទេ ហើយជាការអនុវត្តជាទូទៅនៅក្នុងប្រទេសជាច្រើនដែលមានប្រព័ន្ធតុលាការដែលដំណើរការល្អ។ ទោះជាយ៉ាងណានៅក្នុងករណីដែលបានពិភាក្សានៅក្នុងរបាយការណ៍នេះ ការបង់ប្រាក់សំណងបញ្ចប់រឿងក្តីនេះត្រូវបានធ្វើឡើងក្រោមការយល់ថា ជនរងគ្រោះនឹងដកពាក្យបណ្តឹងព្រហ្មទណ្ឌ ក៏ដូចជាពាក្យបណ្តឹងរដ្ឋប្បវេណី ហើយសកម្មភាពនេះ មិនត្រូវបានអនុញ្ញាតក្រោមច្បាប់កម្ពុជានោះទេ។

យោងតាមក្រមនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា (CCCP) ការដកពាក្យបណ្តឹងរដ្ឋប្បវេណី មិនបានផ្អាកកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនោះទេ។[១០] ច្បាប់ដូចគ្នាបានហាមឃាត់យ៉ាងច្បាស់មិនឲ្យមន្ត្រីនគរបាលទប់ស្កាត់រឿងក្តីព្រហ្មទណ្ឌមិនឲ្យដំណើរការ នៅពេលដែលជនរងគ្រោះបានដកពាក្យបណ្តឹងនោះទេ ឬប្រសិនបើមានដំណោះស្រាយចរចារវាងជនរងគ្រោះនិងជនសង្ស័យ។ មន្ត្រីនគរបាលអាចនឹងទទួលទោសព្រហ្មទណ្ឌប្រសិនបើមន្ត្រីទាំងនោះធ្វើការរារាំងរឿងក្តីព្រហ្មទណ្ឌ។[១១] ក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ[១២] ក៏បានហាមឃាត់ការទទួលសំណូកដោយមន្ត្រីសាធារណៈ[១៣] និងចៅក្រម[១៤] ផងដែរ។ ប៉ុន្តែបទប្បញ្ញត្តិទាំងនេះ គឺកម្រត្រូវបានអនុវត្តណាស់។

ប្រសិនបើរឿងក្តីឈានទៅដល់តុលាការ ពាក្យបណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌនឹងត្រូវបានដោះស្រាយដោយចៅក្រមតែមួយ និងកិច្ចដំណើរការនីតិវិធីតែមួយ ដែលធ្វើឲ្យមានភាពងាយស្រួលសម្រាប់ចៅក្រមក្នុងការចរចារសំណងនៃពាក្យបណ្តឹងរដ្ឋប្បវេណី និងធ្វើការបញ្ចប់បណ្តឹងព្រហ្មទណ្ឌក្នុងពេលតែមួយ។ បទប្បញ្ញត្តិនានានៅក្នុងក្រមនីតិវិធីក្រមព្រហ្មទណ្ឌកម្ពុជា ដែលហាមឃាត់មន្ត្រីនគរបាលមិនឲ្យរារាំងកិច្ចដំណើរការនិតិវិធីនៃរឿងក្តី ទោះជានៅក្នុងព្រឹត្តិការណ៍ដែលមានការចរចាសំណងក៏ដោយ មិនបានគ្របដណ្តប់ទៅដល់មន្ត្រីតុលាការនោះទេ ក៏ប៉ុន្តែបទប្បញ្ញត្តិលើការទទួលសំណូកបានគ្របដណ្តប់លើមន្ត្រីតុលាការ។ ប៉ុន្តែ ករណីអំពើពុករលួយទៅលើចៅក្រម គឺកម្រមានណាស់ ។

[១០] មាត្រា ២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។
[១១] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៧។
[១២] មាត្រា ៣៥ នៃច្បាប់ប្រឆាំងអំពើពុករលួយ ឆ្នាំ ២០១០។
[១៣] មាត្រា ៥៩៤ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។
[១៤] មាត្រា ៥១៧ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩។



## តម្លៃនៃភាពក្រីក្រ

ក្មេងស្រីម្នាក់ អាយុ ១៣ ឆ្នាំ គឺជាជនរងគ្រោះនៃការប៉ុនប៉ងរំលោភសេពសន្ថវៈដោយអ្នកជិតខាងម្នាក់អាយុ ៧០ ឆ្នាំ។ ក្រុមគ្រួសាររបស់ក្មេងស្រី បានរាយការណ៍ករណីនេះទៅនគរបាលថ្នាក់ស្រុក ប៉ុន្តែក្រោយមកបានសម្រេចចិត្តថាពួកគាត់មិនចង់យករឿងក្តីនេះទៅតុលាការ។ ពួកគាត់ក្រីក្រណាស់ និងរស់នៅ ៨០ គីឡូម៉ែត្រ ពីតុលាការ និងមិនមានលទ្ធភាពចំណាយលើការធ្វើដំណើរទៅវិញទៅមកបាននោះទេ។ ដូច្នេះ ពួកគាត់បានចរចារប្រាក់សំណង ៣០០ ដុល្លារ ដោយមានជំនួយពីនគរបាលថ្នាក់ស្រុក។

ស្ត្រីរងគ្រោះដោយអំពីរំលោភសេពសន្ថវៈ

## ផលប៉ះពាល់អវិជ្ជមាននៃការបង់ប្រាក់សំណង

ការរីករាលដាលនៃការប្រើប្រាស់សំណង ដើម្បីដោះស្រាយករណីរំលោភសេពសន្ថវៈ គឺមានផលអវិជ្ជមានជាច្រើនប្រភេទ។ នេះបង្ហាញថា ការរំលោភសេពសន្ថវៈគឺមិនមែនជាបញ្ហាព្រហ្មទណ្ឌ ហើយ មិនធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីត្រូវដោះស្រាយដោយតុលាការនោះទេ។ សកម្មភាពនេះក៏បានធ្វើឲ្យថយចុះឥទ្ធិពលការពាររបស់ច្បាប់៖ ប្រជាពលរដ្ឋកម្ពុជាទាំងអស់ នឹងយល់ថារឿងក្ដីព្រហ្មទណ្ឌអាចត្រូវបានដោះស្រាយដោយសំណងប្រាក់ ហើយជាលទ្ធផល គឺមានការដាក់ទណ្ឌកម្មតិចតួចណាស់ លើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌកម្រិតធ្ងន់ធ្ងរដូចជាការរំលោភសេពសន្ថវៈជាដើម ដែលធ្វើឲ្យមនុស្សមិនសូវរាងចាល។ ម្យ៉ាងទៀត នៅពេលដែលករណីត្រូវបានដោះស្រាយនៅទីស្នាក់ការនគរបាល ព័ត៌មានអំពីករណីទាំងនេះនឹងមិនលេចលឺបន្តទៀតនោះទេ។ នេះមានន័យថា ទិន្នន័យអំពីករណីរំលោភសេពសន្ថវៈដែលត្រូវបានរាយការណ៍ត្រូវបានបាត់បង់ ហើយការរំលោភសេពសន្ថវៈហាក់បីដូចជាបញ្ហាដែលរីករាលដាលតិចតួចជាងការពិត។ ជាលទ្ធផល ធនធានដែលចាំបាច់ដើម្បីចាប់ផ្ដើមដោះស្រាយបញ្ហាទាំងនេះនៅតែមានការខ្វះខាតយ៉ាងខ្លាំង។

# ការរៀបអាពាហ៍ពិពាហ៍ជនរងគ្រោះជាមួយជនសង្ស័យ

នៅក្នុងករណីចំនួន ៧ (២,៥%) នៃករណីជាច្រើនពាក់ព័ន្ធនឹងកុមារ និងករណីចំនួន ៤ (៣%) នៃករណីជាច្រើនពាក់ព័ន្ធនឹងស្ត្រីជនរងគ្រោះត្រូវបានឲ្យរៀបមង្គលការជាមួយជនសង្ស័យ។ ទោះជាករណីទាំងនេះរួមគ្នា គ្រាន់តែជាភាគរយតូចមួយនៃចំនួនករណីសរុបក៏ដោយ ក៏ការពិតដែលការបញ្ចប់ដោយវិធីបែបនេះ គឺជាបញ្ហាគួរឲ្យភ្ញាក់ផ្អើល និងខ្វល់ខ្វាយមួយ។

មូលហេតុដែលអាពាហ៍ពិពាហ៍ ត្រូវបានមនុស្សមួយចំនួនមើលឃើញថា ជាលទ្ធផលដែលអាចទទួលយកបានសម្រាប់ជនរងគ្រោះពីការរំលោភសេពសន្ថវៈ ហាក់ដូចជាតម្លៃស្ត្រីនៅលើតែព្រហ្មចារីយ៍របស់អ្នកទាំងនោះ។ នៅពេលដែលក្មេងស្រីលែងមានព្រហ្មចារីយ៍ នៅក្នុងគំនិតរបស់មនុស្សក្នុងសង្គមនៃប្រទេសកម្ពុជា តម្លៃរបស់នាងនឹងត្រូវបាត់បង់ ហើយអនាគតនាងនឹងក្លាយជាបញ្ហាមួយសម្រាប់គ្រួសាររបស់នាង ទោះបីជាព្រហ្មចារីយ៍របស់នាងត្រូវបានបាត់បង់ដោយការរំលោភសេពសន្ថវៈក៏ដោយ។ សម្រាប់គ្រួសារមួយចំនួន មធ្យោបាយដើម្បីដោះស្រាយបញ្ហារបស់ស្ត្រីដែលមិនអាចរៀបការបានដោយសារបាត់បង់ព្រហ្មចារីយ៍ គឺមានតែឲ្យនាងរៀបការជាមួយបុរសដែលបានរំលោភនាង។ ឪពុកម្ដាយជាច្រើន បានទទួលស្គាល់ថា វាមិនមែនជាមធ្យោបាយដ៏ល្អមួយទេ ប៉ុន្តែអ្នកទាំងនោះមានអារម្មណ៍ថាសង្គមមិនឲ្យជម្រើសអ្វីផ្សេងដល់អ្នកទាំងនោះ ហើយវានឹងប្រសើរប្រសិន បើកូនស្រីរបស់ពួកគេរៀបការជាមួយអ្នកដែលរំលោភនាង ជាជាងក្លាយជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈដោយមិនអាចរៀបការបាន។ សម្រាប់អ្នកទាំងនោះ ការរៀបអាពាហ៍-ពិពាហ៍ គឺជាមធ្យោបាយមួយដើម្បីជួយស្រោចស្រង់កេរ្តិ៍ឈ្មោះកូនស្រីអ្នកទាំងនោះ និងកេរ្តិ៍ឈ្មោះក្រុមគ្រួសារទាំងអស់របស់នាងផងដែរ។

ជាការពិត ការរៀបអាពាហ៍ពិពាហ៍រវាងជនរងគ្រោះ និងជនសង្ស័យ គឺមានហានិភ័យយ៉ាងខ្លាំង។ ជម្រើសក្នុងការរៀបការ ដែលជាលទ្ធផលនៃគំនិតដែលគិតថាតម្លៃរបស់ក្មេងស្រី ស្ថិតនៅលើព្រហ្មចារីរបស់នាង បានកាត់បន្ថយទម្ងន់នៃអំពើល្មើសនៃការរំលោភសេពសន្ថវៈ ហើយស្ថានភាពទាំងនេះនឹងនៅស្ថិតស្ថេរបែបនេះជានិច្ច។ លើសពីនេះ សកម្មភាពនេះ បង្ហាញនូវការមិនយកចិត្តទុកដាក់ចំពោះការរងទុក្ខរបស់ជនរងគ្រោះនោះទេ៖ ទោះជាជនរងគ្រោះមានរបួសផ្លូវចិត្តយ៉ាងណា ក៏នាងត្រូវបង្ខំចិត្តទទួលយកមនុស្សដែលទទួលខុសត្រូវចំពោះរបួសផ្លូវចិត្តរបស់នាងនោះ។ អ្នកទាំងនោះ នៅតែឈឺចាប់ រីឯជនល្មើសទាំងនោះ នៅតែមិនទាន់ត្រូវបានគេដាក់ទណ្ឌកម្ម។

នៅពេលដែលមានការរៀបអាពាហ៍ពិពាហ៍កើតឡើង តែងតែមានការចេញប្រាក់សំណងពីក្រុមគ្រួសាររបស់ជនសង្ស័យ ទៅកាន់ក្រុមគ្រួសារជនរងគ្រោះ។ ប្រាក់ទាំងនេះ មិនត្រូវបានចាត់ទុកជាប្រាក់សំណងការខូចខាតនោះទេ ប៉ុន្តែវាគឺជាប្រភេទមួយនៃតម្លៃរបស់កូនក្រមុំ ដែលកើតឡើងជាទូទៅនៅក្នុងសង្គមកម្ពុជា។ នៅក្នុងករណីមួយចំនួន វាហាក់ដូចជាការរៀបការ និងការផ្ដល់សំណង គឺត្រូវបានចរចាដោយក្រុមគ្រួសាររបស់ជនរងគ្រោះ និងជនសង្ស័យ ដោយមិនមានការចូលរួមពីមេអណ្ដើកនោះទេ ប៉ុន្តែចំពោះករណីភាគច្រើនបំផុត មន្ត្រីសាធារណៈក៏បានចូលរួមផងដែរ ហើយវាហាក់ដូចជាមន្ត្រីទាំងនោះ ប្រហែលជាទទួលបានកម្រៃពីក្រុមគ្រួសារជនសសង្ស័យផងដែរ។ នៅក្នុងករណីចំនួន ៣ ក្នុងចំណោមករណីទាំង ១១ ដែលត្រូវបានលើកឡើងខាងលើ នគរបាលបានជួយចរចាអំពីការរៀបការ ហើយក្នុងករណីទាំងនោះ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សរបស់អង្គការ លីកាដូ បានលឺថានគរបាលទាំងនោះប្រហែលជាទទួលបានប្រាក់។ នៅក្នុងករណីមួយក្នុងចំណោមករណីទាំងនោះ ក្រុមគ្រួសារជនសង្ស័យ បានបង់ប្រាក់ដល់នគរបាល ២.០០០ ដុល្លារ (ក្រុមគ្រួសារជាគ្រួសារអ្នកមានទ្រព្យ ហើយនគរបាលបានប្រាប់អ្នកទាំងនោះថានគរបាលនឹងបញ្ជូនករណីនេះទៅតុលាការ ប្រសិនបើនគរបាលទាំងនោះមិនទទួលបានប្រាក់។ នៅក្នុងករណីចំនួន ៣ ព្រះរាជអាជ្ញា ដើរតួជាមេអណ្ដើកក្នុងការរៀបចំការជួបជុំរវាងគ្រួសារទាំងពីរ។ អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ មិនបានទទួលបានព័ត៌មានអំពីការបង់ប្រាក់នៅក្នុងករណីទាំង ៣ នេះនោះទេ។ នៅក្នុងករណីចំនួន ១ ចៅក្រមជំនុំជម្រះក្ដីម្នាក់ គឺជាភាគីមួយក្នុងការចរចាអំពីការរៀបមង្គលការ និងអនុញ្ញាតឲ្យជនល្មើសរស់នៅខាងក្រៅពន្ធ-នាគារដោយសេរី ហេតុដូចនេះជននោះអាចរៀបការជាមួយជនរងគ្រោះ។ អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ បានលឺពីជនរងគ្រោះថាក្រុមគ្រួសារជនសង្ស័យ អាចបង់ប្រាក់ជូនទៅចៅក្រមនោះ។



## ពីការរំលោភទៅជាការរៀបអាពាហ៍ពិពាហ៍

ក្មេងស្រីអាយុ ១៤ឆ្នាំ ម្នាក់ ត្រូវបានបុរស ៣នាក់រំលោភ។ បុរសម្នាក់ក្នុងចំណោមបុរសទាំងនោះ ត្រូវចាប់បាន និងបញ្ជូនទៅកាត់ទោសក្នុងសវនាការ។ មុនពេលសាលក្រមត្រូវបានប្រកាស ក្រុមគ្រួសាររបស់ជនរងគ្រោះ និងរបស់ជនល្មើស បានឯកភាពគ្នាថាអ្នកទាំងពីរនឹងរៀបមង្គលការ ហើយក្រុមគ្រួសារជនល្មើសនឹងផ្តល់ប្រាក់សំណង ជូនទៅកាន់ក្រុមគ្រួសារជនរងគ្រោះ។ ក្រុមគ្រួសារជនល្មើស ក៏បានផ្តល់លុយទៅចៅក្រមជំនុំជម្រះក្តីក្នុងសវនាការ ដែលជាអ្នកកាត់ទោសជនល្មើសពីបទរំលោភសេពសន្ថវៈ ផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ១៨ខែ ហើយបន្ទាប់មកព្យួរទោសជនល្មើសទាំងអស់។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស បានចូលរួមព្យាយាមផ្តល់យោបល់ដល់ក្រុមគ្រួសារជនរងគ្រោះ ដើម្បីកុំឲ្យសម្រេចចិត្តយល់ព្រមរៀបការ។ម្តាយជនរងគ្រោះបានឆ្លើយតបថាអ្នកស្រីមិនចង់ឲ្យកូនស្រីរបស់អ្នកស្រីរៀបមង្គលការទេ ប៉ុន្តែនៅជនបទ វានឹងល្អប្រសិនបើកូនស្រីអ្នកស្រីរៀបការហើយបន្ទាប់មកលែងលះ ជាជាងនៅជាមនុស្សមិនទាន់រៀបការដែលមនុស្សគ្រប់គ្នាដឹងថានាងត្រូវបានគេរំលោភសេពសន្ថវៈ។

កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈ ចង្អុលបង្ហាញពីកន្លែងកើតហេតុ



អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ សម្ភាសន៍អតិថិជននៅផ្ទះរបស់នាង

# ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

នៅក្នុងករណីចំនួន ១០ ក្នុងចំណោមករណីចំនួន ១៣១ ដែលពាក់ព័ន្ធនឹងស្ត្រីមានអាយុលើសពី ១៨ ឆ្នាំ (៨%) ស្ត្រីត្រូវបានស្វាមីរបស់អ្នកទាំងនោះរំលោភសេពសន្ថវៈ។ នៅក្នុងករណីទាំងអស់នេះ អំពើរំលោភសេពសន្ថវៈ បានកើតឡើងម្តងហើយម្តងទៀត និងជាផ្នែកមួយនៃទម្រង់នៃអំពើហិង្សារយៈពេលវែង ហើយជាការរំលោភបំពានមួយដែលត្រូវបានប្រព្រឹត្តិដោយស្វាមី។ ប៉ុន្តែមានតែករណីមួយប៉ុណ្ណោះ ក្នុងចំណោមករណីទាំងនេះ ដែលមានការបើកសវនាការ និងផ្តន្ទាទោសជនល្មើស។ នៅក្នុងករណីទាំង ៩ផ្សេងទៀត ត្រូវបានបញ្ចប់ដោយ ស្វាមីភរិយាលែងលះគ្នា និងមិនមានការកាត់ទោស។ នៅក្នុងករណីទាំង ៩ នោះ ស្ត្រីសម្រេចចិត្តមិនដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ ឬអ្នកទាំងនោះបានដាក់ ប៉ុន្តែដកពាក្យបណ្តឹងវិញនៅពេលក្រោយមក។ គំនិតរបស់ស្ត្រីដែលសម្រេចចិត្តលែងលះ និងចាកចេញឲ្យឆ្ងាយពីស្វាមីរបស់អ្នកទាំងនោះ ជាជាងការខំប្រឹងប្រែងដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ គឺអាចយល់បាន។ ប៉ុន្តែលទ្ធផលនៃការសម្រេចចិត្តរបស់អ្នកទាំងនោះ គឺជានិទណ្ឌភាពសម្រាប់បុរសជាស្វាមី ដែលបានប្រព្រឹត្តិហិង្សាដោយការរំលោភសេពសន្ថវៈមកលើភរិយា ដែលនេះជាបញ្ហាមួយដែលគួរឲ្យព្រួយបារម្ភ។

ប៉ុន្តែប្រសិនបើស្ត្រីបន្តពាក្យបណ្តឹងព្រហ្មទណ្ឌ លទ្ធផលហាក់ដូចជាមិនទាន់គ្រប់គ្រាន់ទាល់តែសោះដោយសារច្បាប់ពាក់ព័ន្ធនឹងអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ មិនទាន់បានដាក់ទោសឲ្យបានធ្ងន់ធ្ងរគ្រប់គ្រាន់ ទោះជាវាជាអំពើល្មើសដែលបានចែងក្នុងច្បាប់ក៏ដោយ។ និយមន័យនៃអំពើរំលោភសេពសន្ថវៈនៅក្នុងក្រមព្រហ្មទណ្ឌ បានរួមបញ្ចូលអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែក៏មិនបានបញ្ជាក់ថារួមបញ្ចូលនោះដែរ។ ច្បាប់ស្តីពីការការពារអំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះដែលមានអាយុត្រឹមដប់ឆ្នាំ បានទទួលស្គាល់អំពើហិង្សាលើផ្លូវភេទ គឺជាទម្រង់មួយនៃអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែមិនមានបញ្ញត្តិណាមួយចែងអំពីទោសទណ្ឌនោះទេ វាត្រឹមតែចែងថាអំពើហិង្សាក្នុងគ្រួសារនឹងត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌប៉ុណ្ណោះ។ នៅក្នុងការអនុវត្តនេះមានន័យថា ប្រសិនបើការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវបានផ្តន្តាទោស នោះបញ្ញត្តិនៃក្រមព្រហ្មទណ្ឌដែលនឹងត្រូវប្រើប្រាស់ គឺមាត្រា ២២២ ស្តីពីហិង្សាដែលប្រព្រឹត្តិដោយសហព័ន្ធ។ ទោសទណ្ឌសម្រាប់អំពើល្មើសនេះ គឺទោសពន្ធនាគារចំនួន ពី២ឆ្នាំ ដល់ ៥ឆ្នាំ ដែលនេះមានភាពស្រាលជាងទោសរំលោភសេពសន្ថវៈធម្មតា ដែលត្រូវទទួលទោសពន្ធនាគារចំនួន ១០ឆ្នាំ។ ជាក់ស្តែងនៅក្នុងចំណោមករណីទាំង ១០ មានករណីតែមួយ ដែលមានការផ្តន្ទាទោស ជនល្មើសត្រូវបានផ្តន្ទាទោសពន្ធនាគារចំនួនត្រឹមតែ ៣ឆ្នាំ ដោយព្យួរទោស ២ឆ្នាំ។

ទោះបីជាមិនបានល្អឥតខ្ចោះ នៅពេលដែលច្បាប់ទទួលស្គាល់អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ អាកប្ប-កិរិយាសង្គម ហាក់ដូចជាមិនទាន់ទទួលស្គាល់នៅឡើយ ហើយអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សអង្គការ លីកាដូ បានផ្តល់យោបល់ថានគរបាល និងចៅក្រមជាច្រើន នៅតែមិនទាន់ជឿថាមានអំពើរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តដោយស្វាមីលើភរិយានោះទេ។ អាកប្ប-

កិរិយានេះ ក៏ចូលរួមចំណែកមានធ្វើឲ្យស្ត្រីមានភាពរារែកក្នុងការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌផងដែរ។ ឧទាហរណ៍ ស្ត្រីជាច្រើនបានរាយការណ៍អំពីអំពើរំលោភ និងហិង្សាទៅកាន់អាជ្ញាធរ ប៉ុន្តែក្រោយមកដកពាក្យបណ្តឹងវិញ (នៅក្នុងករណីទាំង ៩ ដែលត្រូវបានលើកឡើងខាងលើ គ្រប់ស្ត្រីទាំងអស់ទាំងអ្នកដែលបានជូនដំណឹងនគរ-បាល និងអ្នកដែលបានជូនដំណឹងមេឃុំអំពីអំពើរំលោភ និងហិង្សាហើយនិងអ្នកដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ បានទៅតុលាការដើម្បីលែងលះ)។[១៥] ដូចនេះ នេះជាករណីដែលអាជ្ញាធរ ដឹងយ៉ាងច្បាស់ពីករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។ ទោះបីជាយ៉ាងនេះក៏ដោយក៏នៅតែមានភាពចម្លែកសម្រាប់នគរបាល ឬអាជ្ញាធរ ក្នុងការលើកទឹកចិត្ត ឬគាំទ្រឲ្យស្ត្រីបន្តដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌរបស់អ្នកទាំងនោះនោះដែរ។


អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ ជួបសួរសុខទុក្ខនៅផ្ទះអតិថិជន

# មិនមានពាក្យបណ្តឹងត្រូវបានដាក់ ឬត្រូវបានដក

ក្រុមករណី ចុងក្រោយ[១៦] ដែលជាប្រភេទនៃករណីដែលត្រូវបានបញ្ចប់មុនពេលមានសវនាការ គឺជាករណីដែលជនរងគ្រោះសម្រេចចិត្តមិនដាក់ពាក្យបណ្តឹង ឬបានដាក់ពាក្យបណ្តឹង ប៉ុន្តែក្រោយមកដកពាក្យបណ្តឹងវិញ ដោយមិនទទួលបានសំណង។ ចំនួននៃករណីនេះ គឺមិនកម្រិតតិចតួច ប៉ុន្តែមូលហេតុមួយចំនួនខាងក្រោយការសម្រេចចិត្តរបស់ជនរងគ្រោះ បានបង្កើតឡើងនូវបញ្ហាសំខាន់ៗមួយចំនួន។

មូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ជាច្រើន គឺភាពក្រីក្រ។ ក្នុងចំណោមករណីដែលត្រូវបានបិទជាច្រើន មានតែពីរករណីប៉ុណ្ណោះ ដែលបណ្តឹងត្រូវបានដក ព្រោះជនរងគ្រោះបាននិយាយថាពួកគេមិនមានលទ្ធភាពបន្តបណ្តឹងនេះទេ ប៉ុន្តែអ្នកឃ្លាំ-មើលការរំលោភសិទ្ធិមនុស្សរបស់អង្គការ លីកាដូ បានអះអាងថាអ្នកទាំងនោះមានអារម្មណ៍ថាមូលហេតុនេះ ជាមូលហេតុសាមញ្ញមួយរបស់ជនរងគ្រោះ ក្នុងការបោះបង់ចោលករណីរបស់អ្នកទាំងនោះ។ អ្នកទាំងនោះ បានពន្យល់ថា មូលហេតុព្រោះជនរងគ្រោះរស់នៅតំបន់ជនបទដាច់ស្រយាល ហើយមិនមានលទ្ធភាពធ្វើដំណើរមកកាន់ប៉ុស្តិ៍នគរបាល ចុះទម្រាំមកកាន់តុលាការ។ ក្នុងករណីមួយចំនួនផ្សេងទៀត ជនរងគ្រោះមានអារម្មណ៍ថា អ្នកទាំងនោះមិនមានពេលពេលវេលា។ ឧទាហរណ៍ នៅក្នុងករណីមួយក្នុងចំណោមករណីដែលត្រូវបានបិទទាំងនោះ ជនរងគ្រោះជាកម្មការិនីរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ។ នាងបារម្ភថា ប្រសិនបើនាងសុំច្បាប់ឈប់សម្រាកពីការងារ ដើម្បីទៅប៉ុស្តិ៍នគរបាល ហើយបន្ទាប់មកទៅតុលាការ នាង

[១៥] ប្តីប្រពន្ធជាច្រើន មានការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីប៉ុណ្ណោះ ហើយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់នោះទេ។ ដូចនេះ អ្នកទាំងនោះមិនមានសំបុត្រអាពាហ៍ពិពាហ៍ និងមិនចាំបាច់ទៅតុលាការដើម្បីធ្វើការលែងលះគ្នានោះទេ លុះត្រាតែមានជម្លោះចែកកូន និងទ្រព្យប៉ុណ្ណោះ។

[១៦] មានករណីមួយចំនួនតូចនៅក្នុងប្រភេទនៃករណីដែលត្រូវបានបញ្ចប់មុនពេលមានសវនាការ មិនត្រូវបានលើកឡើងឲ្យបានលំអិតនៅទីនេះ។ ករណីមួយចំនួនក្នុងចំណោមករណីទាំងនោះ ជនសង្ស័យបានរត់គេចខ្លួន ហើយករណីមិនត្រូវបានបន្ត។ ករណីមួយចំនួនទៀត ជនរងគ្រោះដកពាក្យបណ្តឹង ប៉ុន្តែមិនបានដឹងច្បាស់ពីមូលហេតុពិត។

នឹងត្រូវបានគេបញ្ឈប់ពីការងារ។ នាងមានជីវភាពក្រីក្រណាស់ ហើយដូចនេះនាងមិនហ៊ានប្រថុយប្រថាននោះទេ។ នាងបានសម្រេចចិត្តបែបនេះ ទោះជាការពិតដែលបុរសជាអ្នករំលោភសេពសន្ថវៈនាង គឺជាអ្នកធ្វើការងារជាមួយនាងក៏ដោយ។

ក្នុងករណីផ្សេងទៀត ជាពិសេសករណីដែលបានកើតឡើងនៅតាមបណ្តាខេត្តមួយចំនួនជាប់ព្រំដែនប្រទេសថៃ ភាពក្រីក្រផ្តល់ផលប៉ះពាល់អវិជ្ជមានតាមរបៀបផ្សេងៗគ្នា។ នៅក្នុងករណីចំនួន ៣ ជនរងគ្រោះ ក្រោយពេលបានដាក់ពាក្យបណ្តឹង បានធ្វើចំណាកស្រុកទៅកាន់ខេត្តផ្សេងទៀត ឬទៅប្រទេសផ្សេងដើម្បីធ្វើការងារ ហើយជាលទ្ធផល ពាក្យបណ្តឹងរបស់អ្នកទាំងនោះ មិនត្រូវបានបន្តនោះឡើយ។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អង្គការ លីកាដូ បានរាយការណ៍ថាមានករណីមួយចំនួនដែលអ្នកឃ្លាំមើលទាំងនោះបាត់បង់ទំនាក់ទំនងជាមួយជនរងគ្រោះ ហើយថាជនរងគ្រោះអាចធ្វើចំណាកស្រុក ប៉ុន្តែអ្នកទាំងនោះមិនអាចបញ្ជាក់ពីព័ត៌មាននេះបាន។ នៅក្នុងករណីមួយចំនួន ដែលភាពក្រីក្រជាកត្តាមួយ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន អាចជួយក្នុងទំហំមួយជាក់លាក់ ឧទាហរណ៍ ថ្លៃធ្វើដំណើរ ប៉ុន្តែអង្គការទាំងនោះមិនមានធនធានច្រើនដើម្បីជួយជាលក្ខណៈប្រព័ន្ធនោះទេ។

មូលហេតុមួយផ្សេងទៀតដែលជនរងគ្រោះដកពាក្យបណ្តឹង គឺអ្នកទាំងនោះទទួលរងសំពាធក្នុងការធ្វើបែបនេះពីក្រុមគ្រួសាររបស់អ្នកទាំងនោះ ព្រោះជនសង្ស័យជាសមាជិកក្នុងគ្រួសារ។ មានករណីចំនួន ៦ ដែលច្បាស់ថាករណីខាងលើនេះ ជាមូលហេតុនៃការដកពាក្យបណ្តឹង។ ក្នុងនោះ មានករណីចំនួន ៣ ដែលជនរងគ្រោះមានអាយុ ១៨ឆ្នាំ ឬលើសពីនេះ ហើយករណីចំនួន ៣ទៀត ជនរងគ្រោះមានអាយុក្រោម ១៨ឆ្នាំ។ ក្នុងករណីទាំងនេះ ហាក់ដូចជាធម្មតាក្នុងការការពារសមាជិកក្រុមគ្រួសារ ហើយផ្នែកហិរញ្ញវត្ថុ ក៏ជាកត្តាជំរុញផងដែរ នៅពេលដែលជនសង្ស័យជាអ្នករកស៊ីចិញ្ចឹមគ្រួសារ។

នៅក្នុងករណីមួយចំនួន មានភស្តុតាងដែលក្រុមគ្រួសារយ៉ាងតិចណាស់បានបញ្ជូនជនរងគ្រោះ ឬជនសង្ស័យចេញ។ ប៉ុន្តែកត្តាដែលគួរឲ្យសោកស្តាយបំផុតក្នុងករណីទាំងនេះ គឺអាជ្ញាធរជាច្រើននៅតែមិនទាន់បានបន្តនិតិវិធីចោទប្រកាន់។ នៅក្នុងករណីមួយក្នុងចំណោមករណីទាំងនោះ ការសម្រេចចិត្តមិនបន្តនីតិវិធីច្បាប់ ត្រូវបានធ្វើឡើងនៅប៉ុស្តិ៍នគរបាល ដោយមានការដឹងលឺពីនគរបាលទាំងនោះ។ នៅក្នុងករណីពីរផ្សេងទៀត ក្នុងចំណោមករណីទាំងនោះ ជនសង្ស័យ ត្រូវបានជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ហើយ បានដោះលែងវិញដោយព្រះរាជអាជ្ញាតាមរយៈការស្នើសុំពីក្រុមគ្រួសារជនរងគ្រោះ។ នៅពេលដែលអ្នកឃ្លាំមើលសិទ្ធិមនុស្ស អង្គការ លីកាដូ មិនបានទទួលពីព័ត៌មានអំពីការបង់ប្រាក់ក្រៅច្បាប់នៅក្នុងករណីទាំងនេះ អ្នកទាំងនោះបាននិយាយថាវាហាក់ដូចជាមិនអាចទៅរួច ដែលព្រះរាជអាជ្ញាដោះលែងជនសង្ស័យទាំងនោះដោយមិនមានការបង់ប្រាក់។

មូលហេតុមួយចុងក្រោយ ដែលជនរងគ្រោះមានក្នុងការមិនអាចបន្តនីតិវិធីបណ្តឹង គឺពិការភាព ជាពិសេសការគថ្លង់ ឬខ្សោយប្រាជ្ញាក្នុងការរៀន។ នៅក្នុងករណីនេះ អង្គការមិនមែនរដ្ឋាភិបាលជាច្រើន អាចផ្តល់ជំនួយពិសេស ដូចជាសេវាកម្មបកប្រែភាសាគថ្លង់ ប៉ុន្តែសម្រាប់ករណីភាគច្រើន គឺមិនមាននោះទេ។ ជាលទ្ធផល ជនរងគ្រោះមិនអាចបន្តនីតិវិធីបណ្តឹងរបស់អ្នកទាំងនោះបានទេ។ នៅក្នុងករណីមួយ ជនរងគ្រោះជាស្ត្រីគថ្លង់ មានអាយុ ២៧ឆ្នាំ ហើយដោយសារនាងមិនចេះភាសាគថ្លង់ច្បាស់ នាងពឹងផ្អែកលើបងប្អូនស្រីនាងដើម្បីបកប្រែឲ្យនាង។ បងប្អូនស្រីនាង ជាកម្មកររោងចក្រកាត់ដេរម្នាក់ដែលបានជួយនាងដាក់ពាក្យបណ្តឹង។ ប៉ុន្តែដោយសារភាពក្រីក្រ និងអ្នកទាំងពីរមិនមានជំនួយផ្សេងទៀត បងប្អូនស្រីរបស់ជនរងគ្រោះបានសម្រេចចិត្តដកពាក្យបណ្តឹង។ ដូចនៅក្នុងករណីខាងលើ នាងមានអារម្មណ៍ថា នាងមិនអាចប្រថុយប្រថានសុំច្បាប់ឈប់សម្រាកពីការងារដើម្បីជួយក្នុងករណីរបស់បងប្អូនស្រីរបស់នាងបានទេ ព្រោះអាចនឹងបាត់បង់ការងាររបស់នាង។

# បទប្រទូស្តកេរខ្មាស

ប្រភេទទីបីនៃករណីទាំងនេះ គឺជាការផ្តន្ទាទោស និងការលើកលែងទោសជាច្រើនដែលមិនត្រឹមត្រូវ។ ករណីជាច្រើន ដែលមានបទចោទប្រកាន់ដើមគឺជាបទរំលោភសេពសន្ថវៈ ប៉ុន្តែក្រោយមកបែរជាផ្តន្ទាទោសពីបទប្រទូសកេរខ្មាស (បៀតបៀនកេរ្តិ៍ខ្មាស) ទៅវិញ ដែលបានក្លាយជាក្រុមធំមួយនៅក្នុងប្រភេទទីបីនេះ។ យោងតាមមាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌ បទប្រទូសកេរខ្មាស ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយឆ្នាំទៅបីឆ្នាំ ដែលមានលក្ខណៈស្រាលជាងបទល្មើសរំលោភសេពសន្ថវៈ។នៅក្នុងករណីចំនួន៤៧ដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ឆ្នាំ (១៦%) និងនៅក្នុងករណីចំនួន ៧ ពាក់ព័ន្ធនឹងស្ត្រីមានអាយុ ១៨ និងច្រើនជាងនេះ (៥%) មានការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស ទោះជាមានការចោទប្រកាន់ពីជនរងគ្រោះពីអំពើរំលោភ និងចោទប្រកាន់ពីព្រះរាជអាជ្ញាពីបទល្មើសរំលោភសេពសន្ថវៈក៏ដោយ។ នៅក្នុងករណីជាច្រើន មូលហេតុនៃការផ្លាស់ប្តូរបទចោទប្រកាន់ មិនមានភាពច្បាស់លាស់នោះទេ ប៉ុន្តែយោងតាមអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អង្គការ លីកាដូ នេះហាក់ដូចជាមកពីការមិនសូវយល់ពីច្បាប់របស់ចៅក្រម ឬអំពើពុករលួយ។

ក្នុងចំណោមការមិនសូវយល់ដឹងជាទូទៅជាច្រើន ករណីនៃការមិនសូវយល់ដឹងមួយ ដែលអ្នកឃ្លាំមើលសិទ្ធិមនុស្សអង្គការ លីកាដូ បានជួបប្រទះ គឺប្រសិនបើមិនមានភស្តុតាងនៃការរងរបួសធ្ងន់ធ្ងរលើប្រដាប់បន្តពូជ នោះការដាក់បញ្ចូលទៅក្នុងប្រដាប់ភេទស្ត្រីមិនជ្រៅល្មមដើម្បីចាត់ទុកជាអំពើរំលោភសេពសន្ថវៈនោះទេ។ ករណីនេះកើតជាពិសេសចំពោះករណីកុមារី និងស្ត្រីដែលមិនទាន់រៀបមង្គលការ ប្រសិនបើមិនមានភស្តុតាងពីការបាត់បង់សន្ធះព្រហ្មចារីយ៍ ថ្មីៗនោះទេ ចៅក្រមតែងតែសម្រេចផ្តន្ទាទោសក្នុងបទល្មើសដែលស្រាលជាងបទរំលោភសេពសន្ថវៈ។ ប្រសិនបើជនរងគ្រោះពីការរំលោភសេពសន្ថវៈជាច្រើន រងរបួសនៅលើខ្លួនត្រង់កន្លែងផ្សេងមិនមែននៅលើប្រដាប់បន្តពូជ និងពេលខ្លះមិនមានរងរបួសលើរាងកាយទាល់តែសោះ ការសម្រេចចិត្តផ្តន្ទាទោសខាងលើ គឺមិនត្រឹមត្រូវនោះទេ។ បញ្ហា គឺការផ្តោតសំខាន់ទៅលើរបៀបដែលចៅក្រមពិនិត្យមើលភស្តុតាងវេជ្ជសាស្ត្រ។ យោងតាមអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស អង្គការ លីកាដូ ចៅក្រមតែងតែចាត់ទុកលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រទៅលើជនរងគ្រោះ ជាភស្តុតាងសំខាន់បំផុត ហើយនៅក្នុងករណីមួយចំនួន ចាត់ទុកជាភស្តុតាងពាក់ព័ន្ធតែមួយគត់។ នេះ គឺជាការដើរខុសយ៉ាងខ្លាំង៖ ដោយសារភាពភ័យខ្លាច និងខ្មាសគេ ជនរងគ្រោះពីការរំលោភមួយចំនួន ប្រើពេលវេលាយូរដើម្បីរាយការណ៍អំពីអ្វីដែលបានកើតឡើងមកលើអ្នកទាំងនោះ ដូចនេះរបួសរបស់អ្នកទាំងនោះបានជាសះស្បើយទៅហើយ នៅពេលដែលពួកគេបានទៅប្តឹង។ ហើយដូចដែលបានលើកឡើងខាងលើ ជនរងគ្រោះមួយចំនួន ដែលរាយការណ៍ភ្លាមៗ អាចមិនមានការរងរបួសរាងកាយអ្វីទាំងអស់។

លើសពីនេះ អ្នកឃ្លាំមើលអង្គការ លីកាដូ បានរាយការណ៍ថា ការពិនិត្យផ្នែកវេជ្ជសាស្ត្រជាច្រើន គឺជាផ្នែកមួយនៃនីតិវិធីរបស់តុលាការ ដែលមានពាក់ព័ន្ធនឹងអំពើពុករលួយ។ ដោយសារភស្តុតាងនេះ មានលក្ខណៈដាច់ខាត ដូចនេះភស្តុតាងនេះជាមធ្យោបាយដែលជនសង្ស័យអាចប្រើប្រាស់ដើម្បីមានឥទ្ធិពល ទៅលើលទ្ធផលនៃករណីរបស់ជននោះ ហើយមិនមែនជារឿងចម្លែកទេដែលអ្នកត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ ឬ នាយកដ្ឋានសុខាភិបាលក្នុងតំបន់ទទួលសំណូក ដើម្បីធ្វើលទ្ធផលនៃការត្រួតពិនិត្យបញ្ជាក់ថារបួសជនរងគ្រោះ មានលក្ខណៈស្រាលជាងអ្វីដែលបានកើតឡើងពិត។[១៧] លទ្ធផល នៅក្នុងករណីទាំងនេះ គឺតែងតែជាការផ្តន្ទាទោសពីបទ-ល្មើសប្រទូសកេរខ្មាស ជាជាងបទល្មើសរំលោភសេពសន្ថវៈទៅវិញ។



ដៃរបស់កុមារីរងគ្រោះដោយការរំលោភសេពសន្ថវៈ

ការត្រួតពិនិត្យនៃករណីជាច្រើនដែលត្រូវបានបិទ និងដែលត្រូវបានបញ្ចប់ដោយការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស បង្ហាញនូវរបៀបផ្សេងទៀតមួយចំនួន ដែលច្បាប់ស្តីពីការការពារការរំលោភសេពសន្ថវៈ ត្រូវបានគេបកស្រាយខុស។ ករណីចំនួនបួន គឺជាករណីនៃអំពើប៉ុនប៉ងរំលោភសេពសន្ថវៈ ដែលអំពើរំលោភត្រូវបានរារាំងដោយបុគ្គលផ្សេង ឬជនរងគ្រោះតបត និងស្រែក ដែលបណ្តាលឲ្យជនល្មើសរត់គេច។ យោងតាមក្រមព្រហ្មទណ្ឌ អំពើប៉ុនប៉ង ត្រូវបានឲ្យនិយមន័យថា ជាអំពើដែលជនល្មើសមានបំណងនឹងប្រព្រឹត្តបទ

[១៧] តាមមាត្រា ៦៣៩ ហាមឃាត់ការទទួលសំណូករបស់អ្នកអនុវត្តផ្នែកវេជ្ជសាស្ត្រ និងដាក់ទោសពន្ធនាគារពី ២ ទៅ ៥ឆ្នាំ។

ល្មើស ហើយចាប់ផ្តើមប្រព្រឹត្ត ប៉ុន្តែត្រូវបានរារាំងដោយស្ថានភាព ក្រៅខ្លួនដែលមិនមែនជាការគ្រប់គ្រងរបស់ជននោះ។[១៨] នៅក្នុងករណី ដែលអង្គហេតុពិតត្រូវជាមួយនិយមន័យនេះ ការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស គឺជាការបកស្រាយខុសពីក្រមព្រហ្មទណ្ឌ និងផ្តល់ភាពអយុត្តិធម៌ដល់ជនរងគ្រោះ។

ករណីបីផ្សេងទៀត ដែលមានការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស ក៏ផ្តល់នូវព័ត៌មានជាច្រើន៖ ករណីមួយមានជនរងគ្រោះជាក្មេងប្រុសអាយុ ១៦ឆ្នាំ ករណីមួយទៀតមានជនល្មើសជាស្ត្រីម្នាក់ ហើយករណីទីបីពាក់ព័ន្ធនឹងការរួមភេទតាមមាត់ ដែលជនល្មើសដាក់លិង្គរបស់ខ្លួនចូលក្នុងមាត់ក្មេងស្រីអាយុ ៥ឆ្នាំ ម្នាក់ដោយបង្ខំ។ ករណីទាំងបីនេះ គួរតែត្រូវបានផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌពីបទរំលោភសេពសន្ថវៈ។[១៩] ការពិតដែលលទ្ធផលនៃករណីទាំងនេះ ត្រឹមតែការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស មិនត្រឹមតែបង្ហាញអំពី ការមិនសូវយល់ពីច្បាប់របស់ចៅក្រមប៉ុណ្ណោះទេ ថែមទាំងប្រហែលជានៅមានគំនិតបុរាណទៅលើអំពើរំលោភសេពសន្ថវៈផងដែរ៖ មានន័យថាបុរសមិនអាចក្លាយជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈនោះទេ ស្ត្រីមិនអាចប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនោះទេ ហើយការរំលោភតម្រូវឲ្យមានការដាក់ចូល អង្គជាតិបុរសចូលក្នុងប្រដាប់ភេទស្ត្រី។ គំនិតទាំងនេះ គឺជាក់ស្តែងនៅតែស្ថិតនៅរីកសាយ និងតែងតែស្ថិតនៅក្នុងគំនិតចៅក្រមក្នុងសវនាការដដែល។

មូលហេតុចុងក្រោយ ដែលករណីមួយចំនួនត្រូវបានបញ្ចប់ដោយការផ្តន្ទាទោស ពីបទប្រទូសកេរខ្មាស ជាជាងបទរំលោភសេពសន្ថវៈ គឺអំពើពុករលួយ។ ប្រសិនបើជនសង្ស័យម្នាក់ មានលទ្ធភាពបង់ប្រាក់ ការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស គឺជាមធ្យោបាយងាយស្រួលសម្រាប់ចៅក្រមដើម្បីកាត់បន្ថយទង្វន់ទណ្ឌកម្ម ប៉ុន្តែទោសនេះនៅតែជាទណ្ឌកម្មអយុត្តិធម៌ដដែល។ ព័ត៌មានអំពីការបង់ប្រាក់ពីជនសង្ស័យជូនទៅចៅក្រម គឺពិបាកទទួលបានណាស់ ហើយនៅក្នុងករណីជាច្រើនដែលត្រូវបានបិទដោយការផ្តន្ទាទោសពីបទប្រទូសកេរខ្មាស អ្នកឃ្លាំមើលសិទ្ធិមនុស្សអង្គការ លីកាដូ មិនមានភស្តុតាងរឹងមាំអំពីអំពើពុករលួយនៅក្នុងនោះទេ។ ប៉ុន្តែមិនមានការភ្ញាក់ផ្អើលនោះទេ ដោយអំពើនេះជាផលប្រយោជន៍នៃភាគីទាំងអស់ ដើម្បីរក្សាការរៀបចំនេះឲ្យបានសម្ងាត់។ ប៉ុន្តែនៅក្នុងករណីជាច្រើន អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សជាច្រើនបាននិយាយថាអ្នកទាំងនោះជឿថាមានអំពើពុករលួយ ហើយនៅក្នុងករណីមួយចំនួនមានភស្តុតាងរឹងមាំថែមទៀតផង។ ឧទាហរណ៍ នៅក្នុងករណីមួយ ព្រះរាជអាជ្ញាបានចោទប្រកាន់ជនសង្ស័យពីបទរំលោភសេពសន្ថវៈ ហើយបទចោទប្រកាន់នេះ ត្រូវបានបញ្ជាក់បន្ថែមដោយចៅក្រមស៊ើបសួរ។ នៅពេលបើកសវនាការ និងមុនពេលចេញសាលក្រម មេធាវីជនសង្ស័យ បានព្រមព្រៀងជាមួយជនរងគ្រោះថា ជនសង្ស័យនឹងបង់ប្រាក់ជូននាងចំនួន ៩២៥ ដុល្លារអាមេរិក។ បន្ទាប់មកចៅក្រម បានប្រកាសសាលក្រមដោយផ្តន្ទាទោសពីបទប្រទូសកេរខ្មាស និងដាក់ពន្ធនាគារចំនួន ២ឆ្នាំ ដោយព្យួរទោស ១ឆ្នាំ ហើយសម្រេចឲ្យសងសំណងខូចខាតដល់ជនរងគ្រោះចំនួន ៩២៥ ដុល្លារអាមេរិក។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស នៅក្នុងករណីនេះ បានជឿថា ជនរងគ្រោះយល់ព្រមមិនប្តឹងឧទ្ធរណ៍ ជាថ្នូរនឹងការទទួលបានប្រាក់ ហើយចៅក្រមក្នុងសវនាការក៏អាចទទួលបានប្រាក់កម្រៃផងដែរ។ នេះហាក់ដូចជាជនសង្ស័យ ក៏នឹងបានបង់ប្រាក់ជូនព្រះរាជអាជ្ញា និងប្រហែលជូនដល់ចៅក្រមស៊ើបសួរផងដែរ ដើម្បីធានាថាសាលក្រមនឹងមិនត្រូវបានព្រះរាជអាជ្ញាប្តឹងឧទ្ធរណ៍នោះទេ។

[១៨] មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
[១៩] មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា បានចែងថា "គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ"។


ច្រកទ្វារផ្ទះរបស់អតិថិជន អង្គការ លីកាដូ



កុមារីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈ អង្គុយជាមួយម្ដាយ

# អាយុជនរងគ្រោះ

មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ ចែងថាករណីដែលនឹងមានស្ថានទម្ងន់ទោសនៃបទល្មើសរំលោភសេពសន្ថវៈ គឺនៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត "លើបុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ"។[20] ទណ្ឌកម្មនៃបទល្មើសរំលោភសេពសន្ថវៈ ដែលមានស្ថានទម្ងន់ទោសជាប់ពន្ធនាគារ គឺពី ៧ ទៅ ១៥ឆ្នាំ ដែលច្រើនជាងបទល្មើសរំលោភសេពសន្ថវៈធម្មតាដែលត្រូវជាប់ពន្ធនាគារពី ៥ ដល់ ១០ឆ្នាំ។ ពាក្យថា "ទន់ខ្សោយដោយមូលហេតុអាយុនៃបុគ្គល" មិនត្រូវបានឲ្យនិយមន័យឲ្យច្បាស់នៅក្នុងមាត្រានោះទេ ប្រហែលជាចង់ទុកឲ្យចៅក្រមមានឆន្ទានុសិទ្ធិក្នុងការសម្រេច។ ប៉ុន្តែលទ្ធផលនៃកង្វះខាតភាពច្បាស់លាស់នេះ ធ្វើឲ្យមានការផ្តន្ទាទោសដែលមិនស៊ីចង្វាក់គ្នា និងការផ្តន្ទាទោសយ៉ាងស្រាលមួយដែលមិនត្រឹមត្រូវ។ ក្នុងចំណោមករណីចំនួន ២៩៣ ដែលពាក់-ព័ន្ធនឹងកុមារមានអាយុក្រោម ១៨ឆ្នាំ ករណីចំនួន ៣៧ (១៣%) មានលទ្ធផលដោយការផ្តន្ទាទោសពន្ធនាគារតិចជាង ៧ឆ្នាំ។[21]

ពីព្រោះតែភាពខ្វះខាតនិយមន័យ ភាពទន់ខ្សោយដោយមូលហេតុអាយុ អាចត្រូវបានគេបកស្រាយនៅក្នុងន័យជាច្រើន និងដោយយោងតាមច្បាប់ខុសៗគ្នាជាច្រើន។ ទោះចៅក្រមលើកយកនូវមូលហេតុអ្វីក៏ដោយ ក៏នៅតែមិនច្បាស់លាស់ និងមិនស៊ីចង្វាក់គ្នាដដែល។ ករណីចំនួន ៣៧ ដែលត្រូវបានលើកឡើងខាងលើ មានពាក់ព័ន្ធនឹងជនរងគ្រោះដែលមានអាយុក្រោម ១៨ឆ្នាំ ដែលត្រូវបានចែងនៅក្នុងមាត្រានៃអាយុ នៃការទទួលខុសត្រូវព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌ[22] និងជាអាយុនៃអនីតិជនតាមច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។[23] ករណីចំនួន ២៦ ក្នុងចំណោមករណីចំនួន ៣៧ ដែលពាក់ព័ន្ធនឹងជនរងគ្រោះមានអាយុក្រោម ១៥ឆ្នាំ ដែលជាអាយុស្របច្បាប់ក្នុងការរួមភេទយោងតាមច្បាប់ប្រទេសកម្ពុជា។[24] ករណីចំនួន ៧ ពាក់ព័ន្ធនឹងជនរងគ្រោះមានអាយុក្រោម ១០ឆ្នាំ។ ហើយគ្មានករណីណាមួយ ដែលជនល្មើសត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារច្រើនជាង ៦ឆ្នាំនោះទេ ដែលនេះបង្ហាញថាចៅក្រមមិនបានយកចិត្តទុកដាក់ ឬមិនទាន់បានពិចារណាលើមាត្រាស្ដីពីស្ថានទម្ងន់ទោសនៅឡើយ។ ទណ្ឌកម្មដែលតែងតែត្រូវបានធ្វើឡើង គឺការផ្តន្ទាទោសពន្ធនាគារចំនួន ៥ឆ្នាំ ដែលបានកើតឡើងនៅក្នុងករណីចំនួន ២៤ ក្នុងចំណោមករណីទាំង ៣៧ករណី ដែលរួមមានករណីចំនួន ១ ដែលមានជនរងគ្រោះពីរនាក់មានអាយុ ២ឆ្នាំ និង៤ឆ្នាំ។

បញ្ហានៃការផ្តន្ទាទោសយ៉ាងស្រាល នៅក្នុងករណីទាំងនេះដែលមានជនរងគ្រោះជាអនីតិជន ហាក់ដូចជាមានភាពទូទៅនៅក្នុងខេត្តមួយចំនួន ច្រើនជាងខេត្តដទៃទៀត។ នៅក្នុងខេត្តបាត់ដំបងមាន ៩ករណី នៅខេត្តកំពង់ចាមមាន ៦ករណី នៅខេត្តពោធិ៍សាត់មាន

[20] មាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
[21] យោងតាមករណីដែលត្រូវបានបិទក្នុងអំឡុងពេលនោះ នេះមិនអាចធ្វើការសន្និដ្ឋានបាន ថាតើមាត្រានេះ ត្រូវបានយកមកអនុវត្តលើជនរងគ្រោះជាមនុស្សចាស់ ឬយ៉ាងណានោះទេ
[22] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
[23] មាត្រា ៧ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស ឆ្នាំ២០០៨
[24] មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

៥ករណី។[២៥] នៅខេត្តផ្សេងទៀត ដូចជាខេត្តកំពត ស្វាយរៀង និងរាជធានីភ្នំពេញ ចៅក្រមហាក់ដូចជាប្រើប្រាស់កម្រិតទោសជាច្រើន។ នេះហាក់ដូចជា កង្វះខាតភាពច្បាស់លាស់នៅក្នុងច្បាប់ ធ្វើឲ្យមានការផ្តន្ទាទោសមិនស៊ីចង្វាក់គ្នាទៅតាមតំបន់នីមួយៗ។

នៅពេលដែលត្រូវបានសាកសួរ អំពីបញ្ហានៃការផ្តន្ទាទោសស្រាលនៅក្នុងករណីជាច្រើនពាក់ព័ន្ធនឹងអនីតិជន អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សអង្គការ លីកាដូ បានពន្យល់ថា នៅក្នុងបទពិសោធន៍ របស់អ្នកទាំងនោះ ចៅក្រមធ្វើការពិចារណាតិចតួចទៅលើស្ថានទម្ងន់ទោស ហើយតែងតែធ្វើការដាក់ទោសពន្ធនាគារទាបបំផុត ៥ ឆ្នាំ ដោយស្វ័យប្រវត្តិ។ អ្នកឃ្លាំមើលមួយចំនួន បានលើកឡើងថា នៅក្នុងករណីជាច្រើនដែលជនរងគ្រោះមានរូបកាយជាមនុស្សពេញរូបរាង ចៅក្រមតែងតែមិនសូវយកចិត្តទុកដាក់នឹងអាយុរបស់នាង ហើយចាត់ទុកនាងជាមនុស្សពេញវ័យ។

# ការព្យួរទោស

យោងតាមក្រមព្រហ្មទណ្ឌ ទោសពន្ធនាគារអាចនឹងត្រូវបានព្យួរ ប្រសិនបើទោសនោះមានកម្រិតតិចជាង ឬស្មើប្រាំឆ្នាំ។[២៦] លក្ខខណ្ឌតែមួយផ្សេងទៀត គឺជនជាប់ចោទមិនត្រូវបានផ្តន្ទាទោសពន្ធនាគារពីមុនមកក្នុងរយៈពេល ៥ឆ្នាំ។[២៧] ប៉ុន្តែមិនមានការណែនាំអំពីពេលវេលា និងមូលហេតុដែលអនុវត្តការព្យួរទោសនោះទេ។ នេះមានន័យថា នរណាម្នាក់ដែលត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ អាចនឹងទទួលបានការព្យួរទោស ប្រសិនបើអ្នកទាំងនោះត្រូវបានផ្តន្ទាទោសចំនួន ៥ឆ្នាំដែលទោសអប្បបរមា។ ការព្យួរទោសទាំងស្រុង និងមួយផ្នែក បានកើតឡើងលើករណីចំនួន ៧ (៥%) ដែលពាក់ព័ន្ធនឹងស្ត្រីមានអាយុ ១៨ឆ្នាំ ឬច្រើនជាងនេះ និង ១៣ករណី (៤%) ដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ឆ្នាំ។

បញ្ហានៃការផ្តន្ទាទោស ដែលត្រូវបានលើកឡើងខាងលើ គឺមានការពាក់ព័ន្ធនៅទីនេះ។ ក្នុងចំណោមករណីចំនួន ៣៧ មានករណីចំនួន ៣ ដែលជនរងគ្រោះមានអាយុក្រោម ១៨ឆ្នាំ ហើយមានការផ្តន្ទាទោសពន្ធនាគារលើជនល្មើសត្រឹមតែ ៥ឆ្នាំ មួយផ្នែកនៃទោសត្រូវបានព្យួរ។ នៅក្នុងករណីជាច្រើន ដែលបទចោទជាបទរំលោភសេពសន្ថវៈត្រូវបានប្តូរទៅជាបទប្រទូសកេរ្តិ៍ខ្មាសនោះ ការព្យួរទោសក៏អាចត្រូវបានធ្វើឡើងផងដែរ ព្រោះទោសអប្បបរមានៃបទល្មើសនេះគឺត្រឹម ៣ឆ្នាំ ប៉ុណ្ណោះ។ ក្នុងចំណោមករណីជាច្រើន មានករណីចំនួន ៦ ដែលការផ្តន្ទាទោសចុងក្រោយជាបទល្មើសប្រទូសកេរ្តិ៍ខ្មាសនោះ ជនល្មើសបានទទួលការព្យួរទោស។ វាមានអត្ថប្រយោជន៍ក្នុងការពិនិត្យឲ្យបានលំអិតទៅលើករណីមួយចំនួន ក្នុងចំណោមករណីទាំងនេះ ដោយវានឹងបង្ហាញពីកំហុសជាច្រើននៅក្នុងការផ្តន្ទាទោស និងនៅក្នុងករណីមួយចំនួនមានអំពើពុករលួយ ដែលទាំងអស់នេះរួមបញ្ចូលគ្នាធ្វើឲ្យមានលទ្ធផលមិនត្រឹមត្រូវ និងធ្វើឲ្យនីតិវិធីចោទប្រកាន់ទាំងមូលគ្មានន័យ។

នៅក្នុងករណីមួយ ដែលជនរងគ្រោះមានអាយុ ១៤ ឆ្នាំ ហើយមានផ្ទៃពោះបន្ទាប់ពីត្រូវបានគេរំលោភសេពសន្ថវៈ ចៅក្រមបានផ្តន្ទាទោសជនល្មើសឲ្យជាប់ពន្ធនាគារចំនួន ៥ឆ្នាំ ប៉ុន្តែព្យួរទោសចំនួន ២ឆ្នាំ។ នៅក្នុងករណីមួយទៀត ដែលជនរងគ្រោះក៏មានអាយុ ១៤ឆ្នាំ ដែរ ចៅក្រមបានផ្តន្ទាទោសពន្ធនាគារចំនួន ៥ឆ្នាំ ប៉ុន្តែព្យួរទោសចំនួន ៣ឆ្នាំ ហើយនៅក្នុងករណីមួយផ្សេងទៀត ដែលពាក់ព័ន្ធនឹងជនរងគ្រោះអាយុ ៥ឆ្នាំ ចៅក្រមជំនុំជម្រះ បានផ្តន្ទាទោសជនល្មើសឲ្យជាប់ពន្ធនាគារចំនួន ១០ឆ្នាំ ប៉ុន្តែនៅពេលប្តឹងឧទ្ធរណ៍ ទោសនេះត្រូវបានបន្ថយនៅត្រឹម ៥ឆ្នាំ ដោយព្យួរទោសចំនួន ៣ឆ្នាំ។

ករណីដែលមានការផ្តន្ទាទោសពីបទប្រទូសកេរ្តិ៍ខ្មាស គឺជាបញ្ហា។ នៅក្នុងករណីមួយ ដែលមានជនរងគ្រោះជាក្មេងស្រីមានអាយុ ៩ឆ្នាំ។ បទចោទប្រកាន់ដើម គឺជាបទរំលោភសេពសន្ថវៈ ប៉ុន្តែបទចោទនេះ ត្រូវបានប្តូរដោយចៅក្រមទៅជាបទប្រទូសកេរ្តិ៍ខ្មាស។ ជនល្មើស ត្រូវបានផ្តន្ទាទោសពន្ធនាគារចំនួន ៣ឆ្នាំ ប៉ុន្តែចៅក្រមបានសម្រេចឲ្យជាប់តែមួយឆ្នាំប៉ុណ្ណោះដោយព្យួរទោសចំនួន ២ឆ្នាំ។ នៅក្នុងករណីមួយទៀត ដែលមានជនរងគ្រោះអាយុ ៥ឆ្នាំ។ ព្រះរាជអាជ្ញាបានចោទប្រកាន់ជនសង្ស័យពីបទរំលោភសេពសន្ថវៈ ប៉ុន្តែចៅក្រមស៊ើបសួរបានប្តូរបទចោទទៅជាបទប្រទូសកេរ្តិ៍ខ្មាស។ មូលហេតុដែលត្រូវបានផ្តល់ឲ្យ គឺការដាក់បញ្ចូល មិនទាន់ជ្រៅល្មមនឹងអាចចាត់ទុកជាអំពើរំលោភនោះទេ។ នៅក្នុងសវនាការ ជនល្មើសត្រូវបានផ្តន្ទាទោសពន្ធនាគារចំនួន ១៨ខែ ដោយព្យួរទោសចំនួន ១ឆ្នាំ។

ករណីចំនួនពីរផ្សេងទៀត គឺពាក់ព័ន្ធនឹងការប៉ុនប៉ងរំលោភសេពសន្ថវៈ។ ក្នុងករណីទីមួយ ជនរងគ្រោះជាក្មេងស្រីមានអាយុ ១៣ឆ្នាំ។ ព្រះរាជអាជ្ញា បានចោទប្រកាន់ជនសង្ស័យពីបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈ ប៉ុន្តែបទចោទនេះត្រូវបានប្តូរដោយចៅក្រមស៊ើបសួរទៅជាបទប្រទូសកេរ្តិ៍ខ្មាស។ ចៅក្រមក្នុងសវនាការ បានផ្តន្ទាទោសជនល្មើសឲ្យជាប់ពន្ធនាគារចំនួន ២ឆ្នាំកន្លះ ប៉ុន្តែត្រូវព្យួរទោសចំនួន ១ឆ្នាំកន្លះ។ នៅក្នុងករណីចុងក្រោយ ជនរងគ្រោះជាក្មេងស្រីអាយុ ១២ឆ្នាំ។ នៅពេលដែលព្រះរាជអាជ្ញាដំបូងបានចោទប្រកាន់ជនសង្ស័យពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ បទចោទនេះត្រូវបានប្តូរ

[២៥] ដោយនេះការសិក្សាមួយនៃករណីដែលត្រូវបានបិទរបស់អង្គការ លីកាដូ ប៉ុណ្ណោះ នេះមិនអាចធ្វើការសន្និដ្ឋានឲ្យបានរឹងមាំអំពីទម្រង់ជាច្រើននៃការផ្តន្ទាទោសនៅតាមខេត្តខុសៗគ្នានោះទេ។ គំរូត្រឹមត្រូវមួយនៃការផ្តន្ទាទោសពីបទល្មើសរំលោភសេពសន្ថវៈទាំងអស់នៅទូទាំងតុលាការ ត្រូវបានយកមកដើម្បីធ្វើការសន្និដ្ឋានបែបនេះ។
[២៦] មាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
[២៧] មាត្រា ១០៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

### ការអនុញ្ញាតឲ្យមានសេរីភាព

ស្ត្រីអាយុ ៣១ឆ្នាំម្នាក់ បានធ្លាក់ខ្លួនឈឺ និងត្រូវបានបញ្ជូនទៅកាន់គ្លីនិកក្នុងតំបន់ ដោយក្រុមគ្រួសាររបស់នាង តាមរយៈរថយន្តសង្គ្រោះបន្ទាន់។ នៅពេលនាងសម្រាកនៅក្នុងគ្លីនិកនោះ គ្រូពេទ្យបានរំលោភសេពសន្ថវៈលើនាង ដោយប្រើប្រាស់ម្រាមដៃរបស់គាត់ ដាក់បញ្ចូលទៅក្នុងប្រដាប់បន្តពូជរបស់នាង។ ករណីនេះ ត្រូវបានបើកសវនាការ ហើយគ្រូពេទ្យត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ និងដាក់ឲ្យជាប់ពន្ធនាគារចំនួន ៥ឆ្នាំ ប៉ុន្តែទោសទាំងអស់ត្រូវព្យួរ ដែលនេះមានន័យថាគ្រូពេទ្យនោះមិនបានជាប់ឃុំឃាំងក្នុងពន្ធនាគារនោះទេ។

ទៅជាបទប្រទូសកេរខ្មាសដោយចៅក្រមស៊ើបសួរ។នៅក្នុងសវនាការជនល្មើសត្រូវបានផ្តន្ទាទោសពីបទប្រទូសកេរខ្មាស និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចំនួន ២ឆ្នាំ។ ទោសនេះ ត្រូវបានព្យួរទាំងស្រុង ដែលមានន័យថា ជនល្មើសបានជាប់ពន្ធនាគារតែរយៈពេលមួយខែប៉ុណ្ណោះនៅអំឡុងពេលឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។

នៅក្នុងករណីទាំងអស់ដែលបានលើកឡើង អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ជឿថាការព្យួរទោសទាំងនោះ គឺប្រហែលជាលទ្ធផលនៃអំពើពុករលួយដែលបានប្រព្រឹត្តដោយជនល្មើស ក្នុងការបង់ប្រាក់ជូនទៅចៅក្រមកាត់ក្តី។ នេះក៏ហាក់ដូចជាមានការបង់ប្រាក់ជូនទៅព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរផងដែរ ដើម្បីធានាថាអ្នកទាំងពីរមិនប្តឹងឧទ្ធរណ៍ជំទាស់នឹងការផ្តន្ទាទោសនេះ។

ឆន្ទានុសិទ្ធិរបស់ចៅក្រម ជាផ្នែកមួយសំខាន់នៃគ្រប់ប្រព័ន្ធយុត្តិធម៌ ប៉ុន្តែមានការពិបាកក្នុងការរំពៃនូវស្ថានភាពណាមួយដែលសមស្របសម្រាប់អនុវត្តការព្យួរទោស លើជនដែលត្រូវបានផ្តន្ទាទោស ពីបទរំលោភសេពសន្ថវៈណាស់។ លើសពីនេះ ដូចដែលត្រូវបានបង្ហាញតាមរយៈករណីខាងលើ អំណាចក្នុងការសម្រេចព្យួរទោស គឺបង្កឲ្យមានការរំលោភបំពាន និងហាក់ដូចជាបង្កឲ្យមានភាពអយុត្តិធម៌ និងលទ្ធផលមិនត្រឹមត្រូវមួយចំនួន។

# ទោសពន្ធនាគាររយៈពេលខ្លី

នៅក្នុងករណីចំនួន ៧ (៥%) ដែលពាក់ព័ន្ធនឹងស្ត្រីដែលមានអាយុ ១៨ឆ្នាំ ឬច្រើនជាងនេះ និងចំនួន ១២ករណី (៤%) ដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ឆ្នាំ មានការចោទប្រកាន់ និងផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ[២៨] ដែលមានទោសទណ្ឌជាប់ពន្ធនាគារតិចជាងទោសអប្បបរមា ៥ឆ្នាំទៅទៀត។ ដោយផ្អែកលើព័ត៌មានដែលមាន គឺមានការលំបាកដើម្បីស្វែងរកមូលហេតុមួយសម្រាប់ករណីខាងលើនេះ ប៉ុន្តែគួរឲ្យកត់សម្គាល់ដែលក្នុងចំណោមករណីចំនួន ១៩ មានករណីចំនួន៧ គឺជាករណីប៉ុនប៉ងរំលោភសេពសន្ថវៈ។យោងតាមក្រមព្រហ្មទណ្ឌនៅពេលដែលគ្រប់បទល្មើសប៉ុនប៉ងទាំងអស់ ក៏ត្រូវទទួលទោសទណ្ឌផងដែរ[២៩] មិនមានទណ្ឌកម្មជាក់លាក់ណាមួយ ត្រូវបានកំណត់សម្រាប់បទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈនោះទេ។ នេះមានភាពចម្លែក ដោយនៅក្នុងក្រមព្រហ្មទណ្ឌ ក្នុងជំពូកស្តីពីបទល្មើសពាក់ព័ន្ធនឹងផ្លូវភេទ បានចែងនូវអំពើប៉ុនប៉ងប្រព្រឹត្តបទមជ្ឈឹម (ជាបទល្មើសដែលមានកម្រិតមធ្យម) ដែលមានទណ្ឌកម្មដូចនឹងអំពើជាបទមជ្ឈឹមខ្លួនឯងផងដែរ។ ប៉ុន្តែមិនមាននូវមាត្រាចែងពីមានទោសស្មើគ្នាបែបនេះ ចំពោះបទឧក្រិដ្ឋនោះទេ ដូចជាបទល្មើសរំលោភសេពសន្ថវៈជាដើម។ នេះប្រហែលជាមូលហេតុដែលមានទណ្ឌកម្មស្រាលខ្លាំង ចំពោះបទល្មើសប៉ុនប៉ងរំលោភសេពសន្ថវៈ ឧទាហរណ៍ក្នុងករណីដែលមានជនរងគ្រោះមានអាយុ ៧ឆ្នាំ ហើយការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមានចំនួន ១៨ខែ។

[២៨] In all but one of these cases, the sentence was for three years or below so it is possible that some of the convictions were for indecent assault and not rape but that the monitors were unaware of this.
[២៩] មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

# អំពើរំលោភសេពសន្ថវៈដែលមានគ្នាច្រើន

នៅក្នុងអំឡុងពេលសិក្សា ករណីចំនួន ១០ (៨%) ក្នុងចំណោមករណីជាច្រើនដែលពាក់ព័ន្ធនឹងស្ត្រីមានអាយុ ១៨ឆ្នាំ ឬលើសពីនេះ និងករណីចំនួន ៦ (២%) នៃករណីជាច្រើនដែលពាក់ព័ន្ធនឹងកុមារ គឺជាករណីនៃអំពើរំលោភសេពសន្ថវៈដែលមានគ្នាច្រើន។អំពើរំលោភសេពសន្ថវៈដែលមានគ្នាច្រើន មានន័យថាជាអំពើរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តដោយជនល្មើសមានគ្នាច្រើនជាមួយនាក់។ បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើននៃករណីអំពើរំលោភសេពសន្ថវៈដែលមានគ្នាច្រើន គឺប្រសិនបើអ្នកទាំងនោះចូលខ្លួនទៅក្នុងតុលាការ នោះមានលក្ខណៈធម្មតាដែលមានតែជនល្មើសមួយចំនួនប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោស។ មានការផ្តន្ទាទោសក្នុងករណីចំនួន ១២ ក្នុងចំណោមករណីចំនួន ១៦ នៃករណីរំលោភសេពសន្ថវៈដែលមានគ្នាច្រើន ហើយ ៤ករណីក្នុងចំណោមករណីទាំងនោះគឺមានតែជនល្មើសមួយចំនួនប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោស។
ឧទាហរណ៍ នៅក្នុងករណីមួយ ដែលជនរងគ្រោះអាចចាំឈ្មោះបុរសទាំងប្រាំដែលបានរំលោភសេពសន្ថវៈលើនាង ប៉ុន្តែមានតែពីរនាក់ប៉ុណ្ណោះដែលត្រូវបានបើកសវនាការកាត់ទោស និងផ្តន្ទាទោស។ ពេលខ្លះ ជនរងគ្រោះមិនអាចចំណាំជនល្មើសទាំងអស់បាន ដែលធ្វើឲ្យនគរបាលពិបាកស្វែងរក ប៉ុន្តែទោះជាក្នុងករណីដែលជនរងគ្រោះអាចចំណាំជនល្មើសបានទាំងអស់ក៏ដោយ ក៏មានតែជនល្មើសដែលចាប់ខ្លួនបានភ្លាមៗប៉ុណ្ណោះដែលត្រូវបានផ្តន្ទាទោសដោយនគរបាលមិនបានព្យាយាមក្នុងការស្វែងរកជនល្មើសដទៃទៀតនោះទេ។

អំពើរំលោភសេពសន្ថវៈដែលមានគ្នាច្រើន ត្រូវបានចាត់ទុកជាស្ថានទម្ងន់ទោសយោងតាមច្បាប់ប្រទេសកម្ពុជា ដែលនេះមានន័យថាទណ្ឌកម្មជាប់ពន្ធនាគារ គឺចាប់ពី ៧ ដល់១៥ឆ្នាំ។[៣០] ក្នុងចំណោមករណីចំនួន ១២ ដែលមានការផ្តន្ទាទោស មានករណីចំនួន ៦ ដែលការផ្តន្ទាទោសមានកម្រិតធ្ងន់ធ្ងរត្រឹមត្រូវ ប៉ុន្តែករណីចំនួន ៦ទៀត ការផ្តន្ទាទោសមានរយៈពេលក្រោម ៧ឆ្នាំ។ ករណីចំនួន ៤ ក្នុងចំណោមករណីទាំងនោះមានការផ្តន្ទាទោសមានរយៈពេលក្រោម ៥ឆ្នាំ ដែលជាទោសអប្បបរមាសម្រាប់បទល្មើសរំលោភសេពសន្ថវៈដែលត្រូវបានប្រព្រឹត្តដោយជនល្មើសមួយនាក់។ នៅក្នុងករណីភាគច្រើន គឺមិនមានមូលហេតុច្បាស់លាស់ ស្របច្បាប់ ឬមូលហេតុផ្សេងទៀតដែលទោសទណ្ឌមានរយៈពេលខ្លីបែបនេះនោះទេ។

ករណីចំនួន ២ក្នុងចំណោមករណីជាច្រើនអំពើរំលោភដែលមានគ្នាច្រើន មានប្រយោជន៍ក្នុងការពិនិត្យឲ្យបានល់អិត ដោយករណីទាំងពីរ ហាក់ដូចជាបង្ហាញនូវអាកប្បកិរិយាជាក់លាក់មួយគួរឲ្យព្រួយបារម្ភ។ នៅក្នុងករណីមួយ កុមារីអាយុ ១៧ឆ្នាំម្នាក់ បានទៅលេងសង្សាររបស់នាងនៅផ្ទះរបស់គាត់។ នៅទីនោះ នាងត្រូវបានរំលោភសេពសន្ថវៈដោយបុរសចំនួន ៣នាក់ ដែលក្នុងនោះម្នាក់គឺជាសង្សាររបស់នាង ម្នាក់ទៀតគឺជាមិត្តភក្តិរបស់សង្សារនាងដែលនាងអាចចំណាំបាន ហើយម្នាក់ចុងក្រោយនាងមិនអាចចំណាំបាន។ សង្សាររបស់នាង និងមិត្តភក្តិសង្សារនោះ ត្រូវបាននាំខ្លួនចូលសវនាការ ដោយចោទពីបទល្មើសរំលោភសេពសន្ថវៈ ប៉ុន្តែត្រូវបានរកឃើញថាមិនមានទោស។ នៅក្នុងករណីទីពីរ ជនរងគ្រោះជាស្ត្រីអាយុ ៣៥ឆ្នាំម្នាក់ ដែលត្រូវបានសង្សារនាងនាំទៅលេងផ្ទះមិត្តភក្តិរបស់សង្សារនោះ ជាកន្លែងដែលនាងត្រូវបានបុរសទាំងពីររំលោភសេពសន្ថវៈ។ សំណុំរឿងនេះត្រូវបានបើកសវនាការ ហើយទោះបីជាអ្នកទាំងពីរត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈក៏ដោយ ក៏សង្សារនាងត្រូវបានផ្តន្ទាទោសពន្ធនាគារតែចំនួន ១៨ខែ រីឯមិត្តភក្តិរបស់សង្សារនាងត្រូវបានផ្តន្ទាទោសពន្ធនាគារ ១ឆ្នាំ។

យោងតាមចៅក្រមក្នុងករណីទីមួយ កុមារីនោះបានទៅផ្ទះសង្សារនាងដោយខ្លួនឯង និងយល់ព្រមរួមភេទជាមួយសង្សារនោះ។ ជាលទ្ធផល ចៅក្រមសម្រេចថាជនជាប់ចោទទាំងពីរមិនមានកំហុសពីបទល្មើសរំលោភសេពសន្ថវៈនោះទេ។ នៅក្នុងករណីទីពីរ ចៅក្រមមិនបានបញ្ជាក់ច្បាស់ ប៉ុន្តែអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៅក្នុងករណីនេះ មានអារម្មណ៍ថាទោសយ៉ាងស្រាលនេះ គឺដោយសារជនល្មើសម្នាក់ក្នុងចំណោមជនល្មើសទាំងពីរ ជាសង្សាររបស់ជនរងគ្រោះ។ ករណីទាំងនេះ ហាក់ដូចជាបង្ហាញថាចៅក្រមមួយចំនួនប្រកាន់នូវអាកប្បកិរិយារើសអើង ទាក់ទងនឹងទំនាក់ទំនងផ្លូវភេទរបស់ស្ត្រី ហើយសម្រាប់ចៅក្រមទាំងនោះ ឥរិយាបថរបស់ស្ត្រី ជាពិសេសទំនាក់ទំនងសកម្មភាពផ្លូវភេទពីមុនរបស់អ្នកទាំងនោះ គឺជាកត្តាសំខាន់ដើម្បីកំណត់នូវកំហុសរបស់បុរសម្នាក់ ក្នុងបទល្មើសរំលោភសេពសន្ថវៈ។

[៣០] មាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

# សាលក្រមគ្មានទោស

នៅក្នុងករណីចំនួន៣ (៣%) ក្នុងចំណោមករណីជាច្រើន ដែលពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៨ឆ្នាំ និងក្នុងករណីចំនួន ៩ (៧%) ក្នុងចំណោមករណីជាច្រើនដែលពាក់ព័ន្ធនឹងស្ត្រីអាយុ ១៨ឆ្នាំ ឬលើសពីនេះ មានការបើកសវនាការដែលមានលទ្ធផលរកឃើញថា គ្មានកំហុស។ នៅក្នុងប្រព័ន្ធយុត្តិធម៌ដែលដំណើរការត្រឹមត្រូវនានា ជារឿងធម្មតា និងត្រឹមត្រូវពេលដែលករណីមួយចំនួនត្រូវបានចៅក្រមចេញសាលក្រមគ្មានទោស ហើយនៅក្នុងករណីជាច្រើនក្នុងចំណោមករណីទាំង១៦ មិនមានភស្តុតាងដែលបង្ហាញថាការសម្រេចចិត្តរបស់ចៅក្រមមិនត្រឹមត្រូវនោះទេ។ ប៉ុន្តែអ្នកឃ្លាំមើលជាច្រើនរបស់អង្គការ លីកាដូ បានរាយការណ៍ថាការរកឃើញថាគ្មានកំហុស គឺអាចជាលទ្ធផលនៃអំពើពុករលួយ ហើយមានករណីមួយចំនួនតូចក្នុងចំណោមករណីទាំង ១៦ ដែលអ្នកឃ្លាំមើលទាំងនោះគិតថាហាក់ដូចជាមានអំពើពុករលួយ។

នៅក្នុងករណីមួយ ជនរងគ្រោះជាស្ត្រីអាយុ ៦៣ឆ្នាំម្នាក់ និងជនល្មើសជាបុរសអាយុ ៤០ឆ្នាំម្នាក់។ នៅពេលដែលសំណុំរឿងចូលដល់ក្នុងសវនាការ ចៅក្រមបានសម្រេចពន្យាពេលចាប់ផ្តើមសវនាការ ដោយលើកឡើងថាត្រូវការពេលច្រើនដើម្បីប្រមូលភស្តុតាងថែមទៀត។ នៅពេលសំណុំរឿងត្រូវបើកសវនាការម្តងទៀត ចៅក្រមបានរកឃើញថាជនសង្ស័យមិនមានកំហុស។ អ្នកឃ្លាំមើលសិទ្ធិមនុស្សអង្គការ លីកាដូ ដែលបានចូលរួមស្តាប់ក្នុងសវនាការនេះ បាននិយាយថាទាំងព្រះរាជអាជ្ញា និងចៅក្រម ហាក់ដូចជាការពារជនសង្ស័យក្នុងអំឡុងពេលបើកសវនាការ និងមិនផ្តល់ការគាំទ្រដល់ជនរងគ្រោះ ជាអ្នកដែលពិបាកក្នុងការស្វែងរកភស្តុតាងនោះទេ។ នៅក្នុងការការពារក្តីរបស់ជនជាប់ចោទ ជននោះបាននិយាយថាមិនមានមូលហេតុអ្វី ដែលខ្លួនទៅរំលោភសេពសន្ថវៈលើជនរងគ្រោះនោះទេ ព្រោះនាងចាស់ហើយ។ ចៅក្រមបានយល់ស្របនឹងការលើកឡើងរបស់ជនជាប់ចោទនេះ។ អ្នកឃ្លាំមើលសិទ្ធិមនុស្សនៅក្នុងករណីនេះបានជឿថាចៅក្រមបានសម្រេចពន្យាពេលបើកសវនាការ ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទមានពេលវេលាស្វែងរកប្រាក់ចាំបាច់ ដើម្បីសូកប៉ាន់ចៅក្រម និងមន្ត្រីតុលាការផ្សេងទៀត។ នៅក្នុងករណីមួយផ្សេងទៀត ក្មេងស្រីអាយុ ២៣ឆ្នាំ ម្នាក់ ដែលមានភាពខ្សោយប្រាជ្ញាក្នុងការរៀន ត្រូវបានរំលោភចំនួនបីដង ហើយមានផ្ទៃពោះ។ ជនសង្ស័យ ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ និងឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការអស់រយៈមួយឆ្នាំ។ បន្ទាប់ពីមានការបើកសវនាការ ជនសង្ស័យបានបង់ប្រាក់ជូនជនរងគ្រោះចំនួន ៧៥០ ដុល្លារអាមេរិក ហើយនៅពេលដែលសាលក្រមត្រូវបានចេញ ជនជាប់ចោទត្រូវបានប្រកាសថាមិនមានកំហុស។ អ្នកឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការ លីកាដូ ជឿថាហេតុការណ៍នេះបានកើតឡើងព្រោះការបង់ប្រាក់របស់ជនសង្ស័យ ដែលជាអំពើពុករលួយជូនទៅចៅក្រម។ ករណីនេះត្រូវបានគេនិយាយថាមិនមានភស្តុតាងច្បាស់លាស់បញ្ជាក់ពីអំពើពុករលួយរបស់ចៅក្រមនោះទេ ប៉ុន្តែយោងតាមបទពិសោធន៍របស់អ្នកឃ្លាំមើលសិទ្ធិមនុស្សជាច្រើនដទៃទៀត នៅពេលចៅក្រមពន្យាពេលសវនាការ ឬមិនទាន់ចេញសាលក្រម គឺតែងតែជាការទុកពេលក្នុងការចរចាជាមួយជនសង្ស័យ។

នៅក្នុងករណីមួយផ្សេងទៀត ក៏មានបញ្ហាគួរឲ្យព្រួយបារម្ភដែលមានមូលហេតុផ្សេងផងដែរ។ ជនរងគ្រោះជាមនុស្សគថ្លង់ និងចេះភាសាគថ្លង់តែមិនទាន់ស្ទាត់។ នៅក្នុងសវនាការ អង្គការមិនមែនរដ្ឋាភិបាល បានផ្តល់នូវអ្នកបកប្រែភាសាគថ្លង់ដល់នាង ប៉ុន្តែនាងមិនអាចធ្វើការទំនាក់ទំនងឲ្យបានស្ទាត់ ដើម្បីបង្ហាញនូវអ្វីដែលបានកើតឡើងលើនាងទាំងស្រុងនោះទេ។ ជាលទ្ធផល ជនសង្ស័យត្រូវបានរកឃើញថាមិនមានកំហុស។ នេះគឺជាស្ថានភាពលំបាកមួយសម្រាប់ចៅក្រម ដោយសារវាពាក់ព័ន្ធនឹងបញ្ហាសង្គមទូលំទូលាយដែលពាក់ព័ន្ធនឹងការអប់រំមនុស្សគថ្លង់ និងក៏ពីព្រោះវាមិនត្រឹមត្រូវក្នុងការផ្តន្ទាទោសដោយផ្អែកលើភស្តុតាងមិនគ្រប់គ្រាន់។ ប៉ុន្តែការប្រានចោលជនរងគ្រោះដែលគថ្លង់យ៉ាងពេញលេញ ពីការចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌ ដោយផ្អែកលើពិការភាពរបស់អ្នកទាំងនោះបែបនេះ គឺភាពអយុត្តិធម៌យ៉ាងធ្ងន់ធ្ងរ។



អ្នកឃ្លាំមើលរបស់អង្គការ លីកាដូ សម្ភាសន៍អតិថិជន



សមត្ថកិច្ចចង្អុលបង្ហាញ ពីទីកន្លែងរំលោភសេពសន្ថវៈដែលបានកើតឡើង

# សេចក្ដីបញ្ចប់

របាយការណ៍នេះ នាំមកនូវពន្លឺនៃការទន់ខ្សោយយ៉ាងធ្ងន់ធ្ងររបស់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ក្នុងការធ្វើការស៊ើបអង្កេត និងដាក់ទណ្ឌកម្មឲ្យបានត្រឹមត្រូវនៅក្នុងករណីហិង្សាផ្លូវភេទទៅលើស្ត្រី និងកុមារ។ មូលហេតុនៃភាពទន់ខ្សោយនេះ ភាគច្រើនគឺ៖ អំពើពុករលួយ អាកប្បកិរិយារើសអើងចំពោះស្ត្រី និងក្មេងស្រីជាច្រើន ការបកស្រាយច្បាប់ខុស និងកង្វះខាតធនធាន ដែលទាំងអស់នេះរួមបញ្ចូលគ្នាធ្វើឲ្យប្រព័ន្ធនៃនិទណ្ឌភាពមានការរីកដុះដាល និងស្ថិតស្ថេរ។

របាយការណ៍នេះ ក៏បានផ្តោតទៅលើភាពទន់ខ្សោយរបស់ប្រព័ន្ធយុត្តិធម៌ជាជាងបទពិសោធន៍របស់ជនរងគ្រោះម្នាក់ៗ។ យើងមិនត្រូវភ្លេចថា ចំនុចកណ្តាលនៃគ្រប់ករណីទាំងអស់ដែលយើងបានពិភាក្សាគឺស្ត្រី និងកុមារដែលទទួលរងការរំលោភបំពានយ៉ាងហិង្សា និងគួរឲ្យខ្លាច ដែលបណ្តាលឲ្យមានរបួសទាំងផ្លូវកាយ និងផ្លូវចិត្ត។ ភាពទន់ខ្សោយនៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ដើម្បីដាក់ទណ្ឌកម្មដល់អ្នករំលោភបំពានលើជនរងគ្រោះទាំងនោះ មិនបានជួយសំរាលបទពិសោធន៍នៃការរំលោភបំពានរបស់ជនរងគ្រោះនោះទេ ប៉ុន្តែនៅតែធ្វើឲ្យរបួស ដែលអ្នកទាំងនោះដែលធ្លាប់ទទួលរងនៅស្ថិតស្ថេរថែមទៀតផង។ លើសពីនេះទៅទៀត គ្រប់ការខកខានក្នុងការដាក់ទណ្ឌកម្មជនល្មើស នឹងធ្វើឲ្យសាធារណៈជនរឹតតែបាត់បង់ទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌កម្ពុជា និងបង្ហាញជាសារថាអំពើរំលោភសេពសន្ថវៈមិនមែនជាបទល្មើសដែលត្រូវមានវិធានការណ៍តឹងរ៉ឹងនោះទេ។ សកម្មភាព មិនត្រឹមតែធ្វើឲ្យជនរងគ្រោះព្រួយបារម្ភកាន់តែខ្លាំងនោះទេ ហើយថែមទាំងធ្វើឲ្យអនាគតរបស់ជនរងគ្រោះមិនការលំបាក នៅពេលដែលជនរងគ្រោះបានប្រថុយប្រថានរាយការណ៍ពី បទល្មើសដែលត្រូវបានប្រព្រឹត្តមកលើអ្នកទាំងនោះ។

បញ្ហាធ្ងន់ធ្ងរជាច្រើន ត្រូវបានលើកឡើងនៅក្នុងរបាយ-ការណ៍នេះ ប៉ុន្តែអ្វីដែលត្រូវបានផ្តោតភាគច្រើន គឺជាផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរនៃអំពើពុករលួយលើអង្គការអយ្យកា ឬ នីតិវិធីចោទប្រកាន់លើករណីបទល្មើសរំលោភសេពសន្ថវៈ។ ទោះបីជាមួយភាគបីនៃករណីដែលត្រូវបានត្រួតពិនិត្យ មានលទ្ធផលបញ្ចប់ដោយពេញចិត្តក៏ដោយ ក៏ព័ត៌មានលំអិតនៃករណីពីរភាគបីទៀត (និងយោងតាមបទពិសោធន៍ដែលបានរំលឹកឡើងវិញដោយអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សអង្គការ លីកាដូ) នៅតែធ្វើឲ្យមានការលំបាកក្នុងការចៀសពីការទាញសន្និដ្ឋានថា ភាគច្រើននៃមន្ត្រីសាធារណៈ (រាប់ពីនគរបាលក្នុងតំបន់ និងក្រឡាបញ្ជី រហូតដល់គ្រូពេទ្យ និងចៅក្រមនានា) ចាត់ទុកករណីនៃអំពើរំលោភសេពសន្ថវៈ គឺជាមធ្យោបាយរកប្រាក់ចំនូលមួយយ៉ាងល្អទាំងជនរងគ្រោះនិងជនសង្ស័យជាគោលដៅក្នុងការទាញចំណេញ។

កម្ពុជា មានមាត្រាច្បាប់ជាច្រើនសម្រាប់ប្រឆាំងនឹងអំពើពុករលួយដែលប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ប៉ុន្តែមានការអនុវត្តតិចតួចបំផុតក្នុងការអនុវត្តច្បាប់ទាំងនោះ[៣១] និងការពិតជាក់ស្តែង គឺមានការលំបាក់ក្នុងការរាយការណ៍ពីអ្នកដែលផ្តល់សំណូក ដើម្បីឲ្យជននោះទទួលការចោទប្រកាន់តាមផ្លូវច្បាប់។[៣២] លើសពីនេះ មាត្រាច្បាប់ជាច្រើនដែលដាក់ទណ្ឌកម្មដល់ជន ដែលធ្វើឲ្យអាប់ឱនដល់សេចក្តីសម្រេចរបស់តុលាការ[៣៣] (បំណងដើម្បីការពារឯករាជ្យភាពរបស់តុលាការ) បែរជាធ្វើឲ្យមានគ្រោះថ្នាក់ខ្លាំងក្នុងការរិះគន់ការសម្រេចចិត្តរបស់តុលាការទៅវិញ ទោះបីជាការសម្រេចចិត្តនោះមិនត្រឹមត្រូវក៏ដោយ។

អំពើពុករលួយ និងភាពធ្ងន់ធ្ងរនិងស្មុគស្មាញនៃបញ្ហាដទៃទៀត ដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ ទាមទារឲ្យមានការប្តេជ្ញាចិត្តខ្ពស់ និងរយៈពេលយូរមួយពីមន្ត្រីជាន់ខ្ពស់នានាក្នុងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ។ ការប្តេជ្ញាចិត្តនេះ ត្រូវតែធ្វើឡើងតាមរយៈការថ្កោលទោសយ៉ាងច្បាស់លាស់ទៅលើគ្រប់សកម្មភាពនៃហិង្សាលើផ្លូវភេទ ក៏ដូចជាជំហានជាក់ស្តែងនានា ដើម្បីដោះស្រាយបញ្ហាការអនុវត្តច្បាប់មិនពេញលេញដែលត្រូវបានលើកឡើងនៅក្នុងរបាយការណ៍នេះ។ នេះជាការផ្លាស់ប្តូរជាមូលដ្ឋានដែលមានតែរាជរដ្ឋាភិបាលប៉ុណ្ណោះទេដែលអាចធ្វើបាន ដើម្បីធានាថានឹងបញ្ចប់និទណ្ឌភាពសម្រាប់ជនល្មើស លើបទល្មើសរំលោភសេពសន្ថវៈ និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះជាច្រើននាក់។

[៣១] អង្គការតម្លាភាពកម្ពុជា អំពើពុករលួយ និងប្រព័ន្ធអភិបាលកិច្ចកម្ពុជា ឆ្នាំ២០១៤ ទំព័រ ៦២ និង ទំព័រ ៩៤។
[៣២] មាត្រា ៦០៥ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
[៣៣] មាត្រា ៥២៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

## អនុសាសន៍នានា

►►► **ជំហានជាច្រើន គួរតែត្រូវបានអនុវត្ត ដើម្បីធានាថាគ្រប់ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈទាំងអស់ (ទាំងបុរស និងស្ត្រី) មានអារម្មណ៍ជឿជាក់ក្នុងការរាយការណ៍បទល្មើស។ ជំហានទាំងនេះរួមមាន៖**

ទីមួយ៖ មន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល នគរបាល និងមន្ត្រីផ្នែកតុលាការគួរធ្វើការថ្កោលទោសលើអំពើរំលោភសេពសន្ថវៈ និងធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈម្តងហើយម្តងទៀតស្តីពីការប្តេជ្ញាចិត្តរបស់អ្នកទាំងនោះដើម្បីដាក់ទណ្ឌកម្មទៅលើគ្រប់ជនល្មើសទាំងអស់។

ទីពីរ៖ ធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្តីពីគ្រោះថ្នាក់ដែលបណ្តាលមកពីអំពើរំលោភសេពសន្ថវៈ និងស្តីពីច្បាប់ព្រហ្មទណ្ឌស្តីពីបទល្មើសផ្លូវភេទ ដោយប្រើប្រាស់គ្រប់ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងបណ្តាញព័ត៌មានសង្គម និងផ្សព្វផ្សាយដោយផ្ទាល់ទៅកាន់កុមារនៅក្នុងសាលារៀនទៀតផង។

ទីបី៖ ធ្វើកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល (ជាពិសេសក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌) ជាមួយនឹងបណ្តាញអ្នកធ្វើការងារផ្នែកកំសាន្ត ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងនូវការរាយការណ៍របស់អ្នកធ្វើការងារផ្នែកកំសាន្តអំពីអំពើរំលោភសេពសន្ថវៈ និងធានាថាករណីនៃបទល្មើសទាំងអស់នេះត្រូវបានស៊ើបអង្កេត ហើយជនល្មើសទាំងអស់ត្រូវបានផ្តន្ទាទោសតាមច្បាប់ដោយមិនមានផលវិបាកវិលត្រឡប់មកកាន់ជនរងគ្រោះវិញ។

►►► **រាជរដ្ឋាភិបាល គួរតែចាត់វិធានការនានាដើម្បីធានាថាគ្រប់ករណីនៃអំពើរំលោភសេពសន្ថវៈទាំងអស់ ត្រូវបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ និងគ្រប់ឧបសគ្គរាំងនីតិវិធីសវនាការរបស់តុលាការ គួរតែត្រូវបានលុបបំបាត់។ វិធានការទាំងអស់នោះរួមមាន៖**

ទីមួយ៖ ផ្តល់នូវធនធានឲ្យបានគ្រប់គ្រាន់ជូនដល់នគរបាល ដើម្បីធានាថាគ្រប់ករណីនៃបទល្មើសរំលោភសេពសន្ថវៈទាំងអស់ ត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញ និងទាន់ពេលវេលា ភស្តុតាងត្រូវបានប្រមូលឲ្យបានត្រឹមត្រូវ និងគ្រប់ជនសង្ស័យទាំងអស់ត្រូវបានចាប់ខ្លួន។

ទីពីរ៖ ការបង្កើត និងការអនុវត្តនីតិវិធីនានា និងការផ្តល់ការបណ្តុះបណ្តាលដល់នគរបាល ព្រះរាជអាជ្ញា ចៅក្រម និងបុគ្គលិកពេទ្យនានា ស្តីពីរបៀបប្រាស្រ័យទាក់ទងជាមួយជនរងគ្រោះពីបទល្មើសហិង្សាផ្លូវភេទ ទាំងពីរភេទ ជាពិសេសជនរងគ្រោះជាកុមារ រួមទាំងអ្នកដែលមានភាពពិការក្នុងការរៀនសូត្រ ដែលជាអ្នកត្រូវបានសាកសួរ ឬផ្តល់ភស្តុតាងនៅក្នុងតុលាការ ឬប៉ុស្តិ៍នគរបាល។

ទីបី៖ ការបង្កើតនូវមូលនិធិពិសេសរបស់រាជរដ្ឋាភិបាល សម្រាប់ជនរងគ្រោះដែលក្រីក្រមិនមានលទ្ធភាពបន្តនីតិវិធីព្រហ្មទណ្ឌនានា សម្រាប់ចំណាយផ្សេងៗក្នុងករណីនេះដូចជា ថ្លៃធ្វើដំណើរ និងជាប្រាក់សំណងខូចខាតសម្រាប់ចំនួនថ្ងៃធ្វើការងារដែលជនរងគ្រោះបានបាត់បង់ជាដើម។

ទីបួន៖ ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ គួរផ្តល់នូវអ្នកបកប្រែភាសាគថ្លង់ សម្រាប់ជនរងគ្រោះដែលជាមនុស្សគថ្លង់ ដែលចាំបាច់នៅពេលនៅក្នុងប៉ុស្តិ៍នគរបាល និងក្នុងតុលាការ។

ទីប្រាំ៖ ធ្វើការកាត់ទោសឲ្យបានម៉ឺងម៉ាត់ទៅលើគ្រប់ករណីទាំងអស់នៃបទល្មើសហិង្សាលើផ្លូវភេទ ដោយមិនគិតលើឋានៈ ឥទ្ធិពល ឬទ្រព្យសម្បត្តិរបស់ជនល្មើសនោះទេ។ ចាប់ផ្តើម និងបន្តនីតិវិធីស៊ើបអង្កេតដោយព្រះរាជអាជ្ញា ដែលរួមទាំងក្នុងករណីដែលជនរងគ្រោះមិនទាន់បានដាក់ពាក្យបណ្តឹង ឬបានដាក់ប៉ុន្តែក្រោយមកបានដកវិញ។

ទីប្រាំមួយ៖ ពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌចំពោះមន្ត្រីនគរបាលណាដែលមិនបានចាប់ផ្តើមនីតិវិធី ឬរាំងមិនឲ្យចាប់ផ្តើមនីតិវិធីបន្ទាប់ពីទទួលបានការបង់ប្រាក់ក្រៅច្បាប់។

ទីប្រាំពីរ៖ ការពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ ចំពោះមន្ត្រីនគរបាលនានា ត្រង់ចំនុចអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ។

ទីប្រាំបី៖ អនុវត្តគោលការណ៍លើកលែងទោស ចំពោះជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈណាដែលបានទទួលប្រាក់សំណងក្រៅផ្លូវការ ប៉ុន្តែបានរាយការណ៍អំពីអំពើពុករលួយដែលពាក់ព័ន្ធនឹងមន្ត្រីសាធារណៈដែលធ្វើការងារលើសំណុំរឿងរំលោភសេពសន្ថវៈនោះ។

►►► **ជំហាននានា គួរតែត្រូវបានអនុវត្ត ដើម្បីធានាថាសវនាការត្រូវបានប្រព្រឹត្តទៅដោយត្រឹមត្រូវ និងទណ្ឌកម្មត្រូវបានគេអនុវត្តឲ្យបានស៊ីចង្វាក់ និងត្រឹមត្រូវ។ ជំហានទាំងអស់នេះរួមមាន៖**

ទីមួយ៖ ផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រមទាំងចាស់ ទាំងថ្មី ស្តីពីមាត្រានានាក្នុងក្រមព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងបទល្មើសរំលោភសេពសន្ថវៈ ដើម្បីធានាថាចៅក្រមទាំងនោះយល់ដឹងឲ្យច្បាស់ពីអត្ថន័យទាំងស្រុង រួមមានជនរងគ្រោះជាបុរស ការរួមភេទដោយប្រើមាត់ និងជនល្មើសជាស្ត្រី ហើយនិងដើម្បីឲ្យចៅក្រមទាំងនោះបានដឹងអំពីស្ថានទម្ងន់ទោស និងទោសទណ្ឌនានា។

ទីពីរ៖ ការបង្កើតនូវការណែនាំនានាសម្រាប់ចៅក្រម ស្តីពីការដកចេញពីសវនាការនូវភស្តុតាងដែលពាក់ព័ន្ធនឹងប្រវត្តិផ្លូវភេទរបស់ជនរងគ្រោះ លើកលែងតែនៅក្នុងករណីពិសេសនានាដែលពាក់ព័ន្ធនឹងរឿងនេះ។

ទីបី៖ ការបំបែកចេញពីគ្នារវាងធាតុផ្សំផ្នែកករណីព្រហ្មទណ្ឌ និងករណីរដ្ឋប្បវេណី នៃបទល្មើសរំលោភសេពសន្ថវៈ ដូចនេះករណីទាំងពីរនេះអាចត្រូវបានដោះស្រាយដោយតុលាការ និងចៅក្រមពីរប្រភេទផ្សេងគ្នា។

ទីបួន៖ ពង្រឹងការអនុវត្តមាត្រានានានៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពីពុករលួយ ចំពោះចៅក្រម និងព្រះរាជអាជ្ញានានា ត្រង់ចំនុចអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ។

ទីប្រាំ៖ ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យបានច្បាស់ថាបទល្មើសរំលោភសេពសន្ថវៈ ត្រូវរួមមានទាំងអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ហើយអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ មិនគួរត្រូវបានផ្តន្ទាទោសយោងតាមមាត្រាស្តីពីហិង្សាដែលប្រព្រឹត្តដោយសហព័ទ្ធ ឬដៃគូនោះទេ។

ទីប្រាំមួយ៖ បញ្ជាក់ឲ្យច្បាស់នូវអត្ថន័យពាក់ព័ន្ធនឹងជនរងគ្រោះក្នុងឃ្លាថា៖ "ទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ" នៅក្នុងក្រមព្រហ្មទណ្ឌ ត្រង់ចំណុចស្ថានទម្ងន់ទោសសម្រាប់បទល្មើសរំលោភសេពសន្ថវៈ និងផ្តល់ការបណ្តុះបណ្តាលដល់ចៅក្រម ដើម្បីធានាថាមាត្រានេះត្រូវបានអនុវត្តដោយស៊ីចង្វាក់គ្នាគ្រប់ករណីក្នុងពេលកាត់ទោសជនល្មើស។

ទីប្រាំពីរ៖ ធ្វើវិសោធនកម្មច្បាប់ ដើម្បីកំណត់ថាមិនគួរមានការព្យួរទោសចំពោះការផ្តន្ទាទោសលើបទល្មើសរំលោភសេពសន្ថវៈនោះទេ។

ទីប្រាំបី៖ ធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌ ដើម្បីបញ្ចូលមាត្រាដែលកំណត់ថាការប៉ុនប៉ងរំលោភសេពសន្ថវៈនឹងត្រូវទទួលទោសទណ្ឌដូចបទល្មើសរំលោភសេពសន្ថវៈផងដែរ។